ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១២ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៨ | តម្លៃ ១.៥០០៛

## វិធីសាស្ត្រវាស់វែង និងវិភាគពីភាពក្រីក្រ: ករណីសិក្សានៅកម្ពុជា

រៀបរៀងដោយបណ្ឌិត **Hossein Jalilian***

### ១. សេចក្ដីផ្ដើម

ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ វបសអ-CDRI បានផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវ និងឯកសារពិភាក្សាមួយចំនួនស្ដីពីភាពក្រីក្រ និងវិសមភាពនៅកម្ពុជា ហើយឯកសារចុងក្រោយបំផុត គឺការសិក្សាពីការចាកផុតភាពក្រីក្រ (Moving Out of Poverty Study: MOPS)។[១] MOPS បានប្រើវិធីសាស្ត្រខុសពីវិធីសាស្ត្រតាមទំលាប់ ប៉ុន្តែជាទូទៅបានផ្ដល់លទ្ធផលប្រហាក់ប្រហែលគ្នា ។ MOPS និងការសិក្សាផ្សេងទៀតដែលធ្វើឡើងដោយ CDRI និងស្ថាប័នឯទៀត[២] បានបង្ហាញភស្តុតាងដ៏ច្រើនថា អ្នកក្រនៅកម្ពុជាទទួលផលចំណេញមិនបានច្រើនដូចក្រុមចំនួលឯទៀតទេ ពីកំនើនសេដ្ឋកិច្ចល្អវិសេសរបស់កម្ពុជា នៅទសវត្សរ៍ចុងក្រោយនេះ ។ ដូចលទ្ធផលរកឃើញផ្សេងៗទៀតរបស់ CDRI ជាពិសេសការសិក្សាចំនួនពីរ ស្ដីពីការចុះបញ្ជីដីធ្លីដែលទើបចប់សព្វគ្រប់[៣] ការសិក្សានេះក៏បានរកឃើញពីកំណើនវិសមភាពដែរ ។

ទាក់ទិននឹងកត្តាដែលជះឥទ្ធិពលលើភាពក្រីក្រ មានចំណុចមួយចំនួនដែល MOPS ហាក់ដូចមិនបានគាំទ្រដល់ ការយល់ឃើញជាទូទៅនោះទេ ។ ឧទាហរណ៍ នៅភូមិសិក្សាខ្លះ MOPS បានរកឃើញថា អ្នកភូមិមួយចំនួនកាន់តែយ៉ាប់យ៉ឺនឡើង ថ្វីបើជីវភាពរស់នៅ និងសកម្មភាពសេដ្ឋកិច្ចជាទូទៅនៅក្នុងភូមិបានប្រសើរឡើងក្ដី ។ ការសិក្សាក៏រកមិនឃើញចំណងទាក់ទងអ្វីខ្លាំងដែររវាងកម្មសិទ្ធិដីធ្លី និងស្ថានភាពក្រីក្រ។ លទ្ធផលទាំងនេះក៏ដូចជា ការរកឃើញស្រដៀងគ្នាឯទៀត ដែលហាក់ដូចមិនស្របគ្នានឹងឯកសារជាទូទៅ គឺត្រូវតែពិនិត្យឡើងវិញដោយ ធ្វើការស្រាវជ្រាវបន្ថែមទៀត ហើយភាពប្រទាំងប្រទើសគ្នារវាងទិដ្ឋភាពមីក្រូ និង ម៉ាក្រូ ក៏ត្រូវតែដោះស្រាយដែរ ។

អត្ថបទសង្ខេបនេះ មានគោលដៅបញ្ជាក់គាំទ្រដល់ការប្រើប្រាស់វិធីសាស្ត្រខុសៗគ្នាដើម្បីសិក្សាពីភាពក្រីក្រ ព្រមទាំងវែកញែកថា វិធីសាស្ត្រខុសៗគ្នាទាំងនេះភាគច្រើនបំពេញឱ្យគ្នាទៅវិញទៅមក ។ ដោយឡែកការយល់ដឹងទទួលបានពីវិធីសាស្ត្រផ្សេងៗ ដូចជា MOPS ជាដើម នឹងជួយកែលំអគោលនយោបាយម៉ាក្រូ ។ នៅពេលរកឃើញច្បាស់ពីចំណុចប្រទាំងប្រទើសរវាងលទ្ធផលរកឃើញខាងម៉ាក្រូ និងមីក្រូ ស្ដីពីទំនាក់ទំនងរវាងភាពក្រីក្រ និងកត្តាកំនត់ផ្សេងៗទៀត យើងនឹងងាយពិនិត្យឱ្យបានម៉ត់ចត់


*កសិកររើអុសចុះពីរទេះនៅភូមិជនបទមួយ ក្នុងខេត្តកំពង់ឆ្នាំង*

និងពន្យល់បកស្រាយពីភាពខុសគ្នានានា ។ ចំពោះមូលហេតុជាក់លាក់មួយចំនួននៃភាពក្រីក្រ វិធីសាស្ត្រផ្សេងៗដូចជា MOPS និង IDPoor[៤] ជាដើមអាចជួយកំនត់អោយឃើញ និងដោះស្រាយបានកាន់តែសក្ដិសិទ្ធិឡើង ។

អត្ថបទនេះ មានការបែងចែកដូចតទៅ។ ផ្នែកទី២ ពិនិត្យដោយសង្ខេបពីកត្តាកំនត់នានានៃភាពក្រីក្រ។ ផ្នែកទី៣ ពិចារណាពីតួនាទីនៃកំនើនក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ផ្នែកទី៤ បង្ហាញពីវិធីសាស្ត្រយកមកប្រើក្នុង MOPS និងលទ្ធផលរកឃើញដោយសង្ខេបនៃការសិក្សានេះ ។ ផ្នែកទី៥ ពិនិត្យពីសារៈសំខាន់នៃវិធីសាស្ត្រទាំងនោះ។ ផ្នែកទី៦ ពិភាក្សាដោយសង្ខេបពីផលប្រយោជន៍នៃការគួបផ្សំវិធីសាស្ត្រខុសៗគ្នា ។

## មាតិកា

វិធីសាស្ត្រវាស់វែង និងវិភាគពីភាពក្រីក្រ: ករណីសិក្សានៅកម្ពុជា .......... ១
ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ .......... ៥
កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្នាក់ជាតិ: ឧបករណ៍គន្លឹះដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយសមធម៌ .......... ៨
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .......... ១២
— ស្ថានភាពក្នុងប្រទេស .......... ១៤
— សន្ទស្សន៍សេដ្ឋកិច្ច .......... ១៦
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI .......... ២០

* លោក Hossein Jelilian ជានាយកផ្នែកស្រាវជ្រាវនៅ CDRI ។

## ២. កត្តាកំណត់នៃភាពក្រីក្រ

ភាពក្រីក្រជាទូទៅមាន មូលហេតុច្រើនយ៉ាងដែលគេអាចបែងចែកជាប្រភេទធំៗ។ លោក Weiss និង Khan[៥] បានបញ្ជាក់ថា អ្នកក្រមានចំណុចទន់ខ្សោយជាច្រើនមានជាអាទិ :

- កត្តាបុគ្គល ដូចជា ជំនាញទាប អក្ខរកម្មទាប គ្រួសារមានទំហំធំ កង្វះខាតទ្រព្យធន ហើយអាចមាន កត្តាជនជាតិភាគតិច និងយេនឌ័រថែមទៀត។
- កត្តាទីតាំងដូចជាកង្វះលទ្ធភាពបានប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមកិច្ច (ផ្លូវថ្នល់ ទឹកភ្លើង ការថែទាំសុខភាព ការអប់រំ ...)។
- កត្តារចនាសម្ព័ន្ធ ដូចជា កង្វះព័ត៌មានទីផ្សារ សេវាហិរញ្ញវត្ថុ និងឥណទាន។

ចំណុចទន់ខ្សោយរបស់អ្នកក្រអាចមានច្រើនរហូតដល់ មនុស្សច្រើននាក់មិនអាចដោះស្រាយម្ហូបអាហារបានគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវិតទេ ហើយក៏ធ្លាក់ចូលក្នុងទុគ៌តភាព (ក្រីក្រតោកយ៉ាកបំផុត)។ បើសិនគ្មានអន្តរាគមន៍ រឺការកែលំអអ្វីទេ ភាពក្រីក្រវាក្លាយជាអន្ទាក់វិលវង់ គឺអ្នកកើតនៅក្នុងគ្រួសារក្រីក្រ ពិបាកនឹងគេចអោយផុតពី ភាពក្រីក្រណាស់។ នៅកម្ពុជាក៏ដូចជាក្នុងទូទាំងប្រទេសនៅទាបពេក មិនអាចជួយដល់ប្រជាជនមួយភាគធំដែលក្រីក្រនោះទេ។ ដូច្នេះកំណើនសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសសំខាន់ខ្លាំងណាស់ដើម្បីបង្កើតធនធានដ៏ចាំបាច់សំរាប់ដោះស្រាយភាពក្រីក្រ ។

## ៣. សារៈសំខាន់នៃកំណើន សំរាប់ការកាត់បន្ថយភាពក្រីក្រ

ការវិភាគទូទាំងប្រទេស បង្ហាញពីសារៈសំខាន់នៃកំណើនសេដ្ឋកិច្ច ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានច្រើន ។ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ចាំបាច់បំផុតដើម្បីជំរុញជីវភាពអ្នកក្រឱ្យឡើងខ្ពស់ជាងខ្សែបន្ទាត់ក្រីក្រ តាមរយៈការបង្កើតធនធានដែលគេត្រូវការ ។ ជាទូទៅ កត្តាបង្កកំណើន វាក៏ស្រដៀងគ្នានឹងកត្តាដែលជំរុញ ជីវភាពអ្នកក្រឱ្យឡើងខ្ពស់ជាងខ្សែបន្ទាត់ក្រីក្រនោះដែរ។

ការសង្កត់ធ្ងន់លើកំណើន ដែលពេលនេះកាន់តែផ្តោតខ្លាំងលើ "ការទទួលបានកំណើនដ៏ត្រឹមត្រូវ" វាផុសចេញពីការពិតជាក់ស្តែងដែលភាពក្រីក្រ មានលក្ខណៈធ្ងន់ធ្ងរនិងស្រួចស្រាវជាងនៅតាមប្រទេសដែលមាន ផសស ក្នុងមនុស្សម្នាក់ ក៏រិតទាប។ ឧទាហរណ៍ នៅកម្ពុជា ការប៉ាន់ស្មានចុងក្រោយនៃ ផសស ក្នុងមនុស្សម្នាក់ គឺប្រហែល ៤៩០ដុល្លារ។[៦] ទោះបីប្រាក់ចំនូលមានការបែងចែកស្មើភាពក្តី ក៏តួលេខនេះនៅតែទាបដែរ។ ប៉ុន្តែការបែងចែកប្រាក់ចំណូលមានវិសមភាពខ្លាំងណាស់ ហើយបានរុញច្រានប្រជាជនមួយចំនួនធំ (ប្រហែល ៣៥%)[៧] ឱ្យមានចំនូលទាបមិនគ្រប់សំរាប់បំពេញតំរូវការម្ហូបអាហារប្រចាំថ្ងៃផង។ ដើម្បីដោះស្រាយបញ្ហានេះ គេបានអះអាងថា កម្ពុជាគួរដើរតាមមាគ៌ាអភិវឌ្ឍន៍មានមូលដ្ឋានធំទូលាយ និងត្រូវបង្កើនសកម្មភាពសេដ្ឋកិច្ច ធ្វើយ៉ាងណាឱ្យអ្នកក្រអាចចូលរួមជាមួយអ្នកមិនក្រីក្រ ដើម្បីទទួលបានផលចំណេញពីកំណើនឱកាសល្អខាងសេដ្ឋកិច្ច។ តាមរយៈកំណើនកំរិតខ្ពស់និងមានចីរភាព កត្តាខាងបុគ្គល ទីតាំង និង ស្ថាប័ន ដែលបង្កគុណវិបត្តិដល់អ្នកក្រ រំពឹងថានឹងត្រូវកាត់បន្ថយ រឺក៏ដោះស្រាយបានតែម្តង។

ចាប់ផ្តើមពីកំរិតមួយដ៏ទាប ផសស នៅកម្ពុជា បានកើនឡើងគួរជាទីពេញចិត្តក្នុងប៉ុន្មានឆ្នាំថ្មីៗ ដល់ទៅជាង ៧%/ឆ្នាំ ចាប់ពីឆ្នាំ១៩៩៤ មក។ ប៉ុន្តែក្នុងអំឡុងពេលនេះ អត្រាភាពក្រីក្រដែលថយចុះបានច្រើនដែរនោះ គួរតែថយចុះបានច្រើនជាងនេះទៀត យោងតាមកំណើនជាប់រហូត និងការប្រៀបធៀបជាមួយប្រទេសឯទៀតក្នុងតំបន់។ មូលហេតុនៃលទ្ធផលមិនសូវល្អនេះ គឺ លក្ខណៈផ្ទាល់នៃកំណើន និងការពិតជាក់ស្តែងដែលកម្ពុជាមិនទាន់ទទួលបាន កំណើនសេដ្ឋកិច្ចល្អត្រឹមត្រូវ។ បើពិនិត្យឱ្យដិតដល់ពីធាតុផ្សំនៃកំណើនជាពិសេស លទ្ធផលវិស័យកសិកម្មដែលជា ប្រភពចំនូលរបស់អ្នកក្រភាគច្រើន គេឃើញមានកត្តាឃឹតយ៉ាវមួយចំនួន។[៨]

កត្តាម៉ាក្រូដែលរារាំងដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា មានជាច្រើន ហើយកំហិតចំបងគេ គឺ ស្ថានភាព និងកំណើនយឺតនៃកសិកម្ម។ ដើម្បីឱ្យការកាត់បន្ថយភាពក្រីក្រជឿនលឿនទៅមុខ កំណើននិងផលិតភាពកសិកម្មត្រូវតែកែលំអយ៉ាងច្រើនថែមទៀត ពីព្រោះកន្លងមក កំណើនកសិកម្មជាទូទៅប្រែប្រួលមិនទៀងទាត់សោះ និង ដើរយឺតជាងវិស័យឯទៀតៗ ។

លក្ខខណ្ឌសំខាន់មួយដើម្បីឱ្យវិស័យកសិកម្ម ស្ថិតក្នុងមាគ៌ាកំណើនខ្ពស់និងមានចីរភាព គឺរឿងដីធ្លី។ ការសិក្សារបស់ CDRI លើការចុះបញ្ជីដីធ្លីដូច បានបញ្ជាក់ខាងលើ បានគាំទ្រយ៉ាងខ្លាំងដល់ការងារចុះបញ្ជីដីធ្លី និងបានបង្ហាញពីកំណើនវិសមភាពក្នុងការកាន់កាប់ដី ។ ដើម្បីធ្វើឱ្យវិស័យកសិកម្មរឹងមាំឡើង គេត្រូវពន្លឿនដំណើរការចុះបញ្ជីដីធ្លី និងដោះស្រាយបញ្ហាវិសមភាពកាន់កាប់ដីជាសំខាន់ ។ ភស្តុតាងពីប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបង្ហាញថា ប្រទេសដែលមានកំណើនប្រកបដោយចីរភាព និងការអភិវឌ្ឍលឿន គេមានការបែងចែកដីធ្លីប្រកបដោយសមធម៌ជាង ហើយកត្តានេះជះឥទ្ធិពលល្អច្រើនយ៉ាងដែលមានរាយការណ៍យ៉ាងច្បាស់ ។ សំរាប់ប្រទេសមួយស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដូចជាប្រទេសកម្ពុជាយើងនេះ ការមានកម្មសិទ្ធិដីជាទូទៅគ្រប់គ្នា គឺជាគ្រឿងលើកទឹកចិត្តដ៏ចាំបាច់ដើម្បីឱ្យមានការកែលំអផលិតភាពដី ។ ប៉ុន្តែរឿងនេះអាចកើតមានឡើងបាន លុះត្រាតែមានការផ្តល់គ្រឿងលើកទឹកចិត្តនិងការគាំទ្រខាងស្ថាប័នផ្សេងៗទៀត ។ឧទាហរណ៍ សិទ្ធិអចលនទ្រព្យដែលបានកំនត់យ៉ាងល្អនិងច្បាស់ ការពង្រឹងនីតិរដ្ឋដើម្បីបង្កើនសុវត្ថិភាពកាន់កាប់ដីរបស់កសិករ អាចជំរុញឱ្យពួកគេ កែលំអដីធ្លីរបស់ខ្លួន និងប្រើប្រាស់ដីកាន់តែមានប្រសិទ្ធភាព។ កត្តាជំរុញផ្សេងទៀត មានជាអាទិ ការផ្តល់ប្រព័ន្ធស្រោចស្រព ការអប់រំពីរបៀបប្រើប្រាស់គ្រាប់ពូជនិងបច្ចេកទេសល្អប្រសើរ លទ្ធភាពទទួលបានទុនហិរញ្ញវត្ថុ សាលារៀន និងមជ្ឈមណ្ឌលសុខភាព ។ ទាំងអស់នេះរំពឹងថា នឹងលើកទឹកចិត្តប្រជាជនជនបទឱ្យដើរតួនាទីកាន់តែ សកម្មនៅក្នុងផលិតកម្ម និងអភិវឌ្ឍន៍។ នៅក្នុងដំណើរការនេះ ប្រាក់ចំនូលដែលមានទាំងប្រាក់ចំនូលរបស់អ្នកក្រនៅជនបទផង នឹងមានការកើនឡើង ។

កំណើនសេដ្ឋកិច្ចត្រូវមានជាចាំបាច់ ប៉ុន្តែកំណើនតែម្យ៉ាងមិនគ្រប់គ្រាន់ដើម្បីកាត់បន្ថយភាពក្រីក្រទេ ។ កំណើនអាចជះឥទ្ធិពលដល់ភាពក្រីក្របានប៉ុណ្ណា វាអាស្រ័យលើប្រភេទនៃកំណើន ។ ក្នុងកំណើនមានលក្ខណៈរាប់បញ្ចូល (inclusive) ដែលក្នុងនេះភ្នាក់ងារទាំងអស់ទទួលផលបានស្មើៗគ្នា ការកាត់បន្ថយភាពក្រីក្រ អាចបានលទ្ធផលច្រើនបំផុត។ បើសិនកំណើនវាមិនរាប់បញ្ចូល រឺអំណោយផលដល់អ្នកក្រទេ ឥទ្ធិពលកាត់បន្ថយភាពក្រីក្រទំនងមានតិចតួចប៉ុណ្ណោះ។ ក្នុងស្ថានភាពបែបនេះ កំណើនអាចបង្កើនវិសមភាព ហើយក៏ប៉ះពាល់អវិជ្ជមានដល់ការប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ជាពិសេស សេដ្ឋកិច្ចនយោបាយ រចនាសម្ព័ន្ធស្ថាប័ននិងអភិបាលកិច្ច ព្រមទាំង សក្តានុពលអភិវឌ្ឍន៍ក្នុងរយៈពេលវែង។ កំណើនមានលក្ខណៈ រាប់បញ្ចូល រឺអត់ វាជាប់ទាក់ទងជាសំខាន់ទៅនិងរចនាសម្ព័ន្ធស្ថាប័ន និងអភិបាលកិច្ច ។ កំណើនតែម្យ៉ាង អាចមិនគ្រប់គ្រាន់ទេ ដើម្បីដោះស្រាយមូលហេតុនៃភាពក្រីក្រដែលពាក់ព័ន្ធនិងរចនាសម្ព័ន្ធ រឺទីតាំង។ ដូច្នេះដើម្បីដោះស្រាយភាពក្រីក្រ គេត្រូវមានវិធីសាស្ត្រកានតែផ្តោតខ្លាំង និងចំគោលដៅ។ ដើម្បីកសាងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រមានប្រសិទ្ធភាពខ្ពស់ គេត្រូវរកឱ្យឃើញ និងយល់ឱ្យច្បាស់ពីលក្ខណៈខុសៗគ្នានៃភាពក្រីក្រ និងមូលហេតុរបស់វា។ MOPS និងវិធីសាស្ត្រវិភាគពីភាពក្រីក្រ

ស្រដៀងៗគ្នា ដូចជា គំរោងកំនត់ភាពក្រីក្រ (IDPoor Project) ជាដើម ក៏ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះដែរ ។

## ៤. វិធីសាស្ត្រ MOPS និងលទ្ធផលរកឃើញ

MOPS គឺជាការសិក្សាលើប្រធានបទបែបនេះលើកទី១ នៅប្រទេសកម្ពុជា និងជាការសិក្សាមួយក្នុង ចំណោមការសិក្សាទាំង ១៨ ដែលធនាគារពិភពលោក បានចុះកិច្ចសន្យាប្រគល់ឱ្យធ្វើ ដើម្បីពិនិត្យពីនិន្នាការ និងឌីណាមិកនៃភាពក្រីក្រ ។ ការសិក្សានេះធ្វើឡើងក្នុងឆ្នាំ២០០៤/០៥ នៅតាមភូមិចំនួន ៩ ដែល CDRI បានចុះស្រាវជ្រាវម្តងរួចមកហើយកាលពីឆ្នាំ២០០១ ដោយប្រើវិធីសាស្ត្របែបគុណភាព និងបរិមាណ ដើម្បីតាមដានពីកិរិតដែលភូមិទាំងនេះ ក៏ដូចជាគ្រួសារនីមួយៗអាចចាកផុតពីភាពក្រីក្រ និងបានធូរធារឡើង រឺក៏បានចុះក្រីក្របែថមទៀត ។

ការសិក្សាមានគោលដៅពិនិត្យថា តើសហគមន៏ រឺក្រុមណាមួយបានចាកផុតពីភាពក្រីក្រ និងតើសហគមន៏ រឺក្រុមណាមួយនៅតែជាប់ផុងក្នុងភាពក្រីក្រ ហើយហេតុអ្វី? តើប្រជាជនមានការវិវត្តខុសគ្នានៅក្នុងស្ថានភាពសេដ្ឋកិច្ចខុសៗគ្នារឺយ៉ាងណា? តើអភិបាលកិច្ច និងបណ្តាញសង្គមកិច្ចសំខាន់ប៉ុណ្ណាក្នុងការវិវត្តឡើងរបស់ប្រជាជន ហើយហេតុអ្វី? តើកត្តាអ្វីខ្លះជួយឱ្យសហគមន៏ និងគ្រួសាររីកចំរើននិងវិវត្តឡើង រឺក៏ចុះក្រនិងជាប់ផុង? តើមានអន្តរកម្មអ្វីខ្លះរវាងកត្តាសហគមន៏ និងគ្រួសារ រឺក៏មានការប្រែប្រួលខុសគ្នាអ្វីដែររវាងភូមិនានា និងគ្រួសារប្រភេទខុសៗគ្នា? ។

ការសិក្សាប្រើវិធីសាស្ត្រតាមបណ្តោយពេល (longitudinal) ដោយចុះសិក្សាលើគ្រួសារដែលធ្លាប់បញ្ចូលក្នុង ការសិក្សានៅឆ្នាំ២០០១ រួចហើយ ។ ការសិក្សាបានពិនិត្យលើបរិបទ ដោយធ្វើការស្រាវជ្រាវពីប្រវត្តិក្នុងមូលដ្ឋានភូមិសាស្ត្រ និងនិន្នាការប្រែប្រួល ព្រមទាំងស្រាវជ្រាវពីឥទ្ធិពលនៃកត្តាទាំងនេះ ទៅលើសហគមន៏និងគ្រួសារ ។ ការសិក្សាបានប្រើវិធីសាស្ត្រចំរុះ ដែលមានទាំងការអង្កេតគ្រួសារជាក្រុម ការពិភាក្សាស៊ីជំរៅនៃក្រុមគោលដៅ និងបទសំភាសន៏ពាក់កណ្តាលរៀបរយ។ ភូមិទាំង ៩ ដែលបានជ្រើសរើសសំរាប់ការសិក្សាដំបូងនៅឆ្នាំ២០០១ តំណាងអោយតំបន់កសិ-អេកូឡូស៊ីជនបទសំខាន់ៗចំនួន ៤ នៅកម្ពុជា គឺមាន វាលទំនាបទន្លេសាប វាលទំនាបទន្លេមេគង្គ តំបន់ភ្នំ/ខ្ពង់រាប និងតំបន់ឆ្នេរ ។ ក្រុម ៨៩០គ្រួសារ ដែលស្រង់យកពីភូមិសិក្សាទាំង ៩ បង្កើតបានជាកំរងទិន្នន័យដ៏សំខាន់មួយ ដែលគេអាចប្រើប្រាស់ដើម្បីធ្វើការអះអាងពីនិន្នាការសរុប និងនិន្នាការតាមភូមិ ដែលមានតំលៃគ្រប់គ្រាន់ខាងស្ថិតិ ។ អង្កេតជាក្រុម ត្រូវបានបំពេញបន្ថែមដោយទិន្នន័យគុណភាពបានមកពីបទសំភាសន៏ និងក្រុមគោលដៅ ដែលមានអ្នកចូលរួម ៤៧៧នាក់ ដូចជា អ្នកដឹកនាំផ្លូវការនិងមិនផ្លូវការក្នុងភូមិក្រុមចលនា (គឺមាន អ្នកចូលរួមដែល ធ្លាក់ចូលភាពក្រីក្រ រឺចាកផុតភាពក្រីក្រ រឺមានស្ថានភាពនៅដដែល) និង បុរស-នារីវ័យក្មេង ។

ការវិភាគ រួមមាន ការពិនិត្យពីការផ្លាស់ប្តូរ និងនិន្នាការសំខាន់ៗដែលជះឥទ្ធិពលលើភូមិសិក្សា ដូចជា បំរែបំរួលក្នុង ការប្រើប្រាស់ ប្រាក់ចំណូល និងអត្រាក្រីក្រ ព្រមទាំង ការវិភាគពីកត្តាជួយជំរុញ រឺរារាំងការរីកចំរើន/ការអភិវឌ្ឍសហគមន៏ និងចលនាគ្រួសារធ្លាក់ចូលរឺចាកផុតភាពក្រីក្រ។ ការវិភាគអនុវត្តលើកត្តាសហគមន៏ ដូចជា ស្ថានភាពនៅមូលដ្ឋាន និងបរិបទអភិវឌ្ឍន៏/អភិបាលកិច្ចដែលកំណត់ការវិវត្តតាមភូមិនីមួយៗ និងអនុវត្តលើកត្តាគ្រួសារដូចជា យុទ្ធសាស្ត្រសំរាប់ការបង្កើតប្រាក់ចំណូល និងភាពងាយរងគ្រោះដ៏ជាក់លាក់របស់គ្រួសារនីមួយៗ ។

ការសិក្សារកឃើញថា និន្នាការខាងសុខមាលភាពប្រែប្រួលខុសគ្នាគួរអោយកត់សំគាល់រវាងភូមិ និងគ្រួសារនានា។ គិតជាតួលេខសរុប ប្រាក់ចំណូល និងចំណាយលើការប្រើប្រាស់កើនឡើង ហើយភាពក្រីក្រថយចុះបន្តិច ។ ផ្ទុយទៅវិញ ដូចលោកស្រី Fitzgerald និងលោក សូ សុវណ្ណារិទ្ធិ បានលើកបញ្ជាក់ ប្រាក់ចំណូលបានកើនឡើងនៅ គ្រប់ភូមិសិក្សា រីឯចំណាយលើការប្រើប្រាស់ថយចុះក្នុង ៣ភូមិ និងកើនឡើងក្នុង ៦ភូមិទៀត។ ចំនួនគ្រួសារក្រីក្រ ធ្លាក់ចុះក្នុង ៦ភូមិ និងកើនឡើងក្នុង ៣ភូមិដែលមានការថយចុះចំណាយប្រើប្រាស់។

ការសិក្សារកឃើញថា ពីឆ្នាំ២០០១ ដល់ ២០០៤/០៥ គ្រួសារជាង ៥០% គ្មានការផ្លាស់ប្តូរស្ថានភាពទេ។ ក្នុងចំណោម ៤៨% ដែលនៅសល់ គេឃើញ ២៦% មានជីវភាពប្រសើរឡើង និង ២២% កាន់តែចុះក្រ ដូច្នេះសរុបមកគឺមានចលនាឈានឡើងសុទ្ធ ៤% ក្នុងអំឡុង ៣,៥ឆ្នាំ ដែលជាចន្លោះពេលរវាងអង្កេតទាំងពីរ។ សំរាប់គ្រួសារគ្មានចលនា មាន ២៤% (នៃគំរូតាងសរុប)នៅតែធូធារ ១៤%នៅតែក្រីក្របង្គួរ និង ១៤%នៅតែជាប់ផុងក្នុងភាពក្រីក្រ (ក្ររហូត)។ សំរាប់គ្រួសារមានចលនា មានគ្រួសារ ១៤% (នៃគំរូតាងទាំងមូល)ដែល កាលពីមុនក្រីក្រខ្លាំងហើយបានឈានឡើងជាក្រីក្របង្គួររឺធូរធារ(ចាកផុតភាពក្រីក្រ)នៅឆ្នាំ២០០៤/០៥ គ្រួសារ ៧% ដែលពីមុនក្រីក្របង្គួរបានក្លាយជាក្រីក្រខ្លាំង(ចុះក្រ) និង ១២% បានក្លាយជាអ្នកធូរធារ ។ ម្យ៉ាងទៀតមានគ្រួសារ ១៥%ដែលកាលពីមុនជាអ្នកធូរធារហើយក្លាយជាក្រីក្របង្គួររឺក្រីក្រខ្លាំង ។

បើគិតតាមការវាស់វែងផ្សេងៗទៀតក្រៅពីចំណាយប្រើប្រាស់ (ដូចជាប្រាក់ចំណូល ទ្រព្យធននិងការទទួលបានបណ្តាញ ធនធាននិងការសំរេចចិត្ត) ការសិក្សារកឃើញថា វិសមភាពបានកើនឡើង ពីឆ្នាំ២០០១ ដល់ ២០០៤/០៥ ។ ខណៈដែលវិសមភាពចំណាយប្រើប្រាស់នៅថេរ ហើយវិសមភាពកាន់កាប់ដីធ្លីថយចុះ វិសមភាពប្រាក់ចំណូលបានកើនឡើង ហើយអនុបាតរវាងតំលៃទ្រព្យកាន់កាប់ដោយអ្នកធូរធាររហូត និងអ្នកក្រីក្ររហូត ក៏កើនឡើងដែរ។ គ្រួសារក្រីក្រកាន់តែក្រដាច់ឆ្ងាយពីគេខ្លាំងឡើង ហើយចំណាយប្រើប្រាស់របស់ពួកគេកាន់តែចុះទាបឆ្ងាយពីបន្ទាត់ ក្រីក្រ ។ កំនើនវិសមភាព ជាការព្រួយបារម្ភសំរាប់គ្រប់ភូមិសិក្សា ហើយអ្នកចូលរួមក្នុងក្រុមគោលដៅ បានផ្តល់មតិថា ការគួបផ្សំគ្នារវាងធនធានសេដ្ឋកិច្ច និង អំណាច/ឥទ្ធិពលខាងសង្គមកិច្ច-នយោបាយ បានបង្កនិន្នាការនេះឡើង ពីព្រោះ ធនធាន ឱកាសល្អ និងសេវាកម្មកាន់តែប្រមូលផ្តុំច្រើនឡើងក្នុងដៃគ្រួសារធូរធារនានា ។

ទោះបីការបញ្ចប់ជំលោះតាមផ្លូវអាវុធនៅចុងទសវត្សរ៏១៩៩០ ជាកត្តាមួយដ៏សំខាន់សំរាប់អភិវឌ្ឍន៏ភូមិក៏ពិតមែន ប៉ុន្តែ ទីតាំង ផ្លូវទាក់ទង និងលក្ខណៈភូមិសាស្ត្រនៃភូមិសិក្សា កាន់តែសំខាន់ថែមទៀតសំរាប់សុខមាលភាពរបស់សហគមន៏ ។ ភូមិមានដំណើរការខ្លាំង តែងមានទីតាំងនៅជិតផ្លូវជាតិ/ទីរួមខេត្ត មានផ្លូវល្អ ដីមានផលិតភាព និងមានប្រព័ន្ធធារាសាស្ត្រ រីឯភូមិមានដំណើរការបង្គួរ តែងនៅដាច់ស្រយាលជាង មានដីអន់ជាង ដីសំរាប់ដាំដុះតិចជាង និងគ្មានប្រព័ន្ធធារាសាស្ត្រទេ ។ លើសពីនេះ ចលនាឈានឡើង រឺធ្លាក់ចុះរបស់គ្រួសារក្នុងភូមិ គឺស៊ីគ្នានឹងនិន្នាការអភិវឌ្ឍន៏របស់ភូមិ។ ភូមិមានដំណើរការខ្លាំង មានអ្នកធូរធារច្រើន និងមានគ្រួសារឈានឡើងច្រើន រីឯភូមិមានដំណើរការអន់ មានអ្នកក្រច្រើន និងមានគ្រួសារធ្លាក់ចុះច្រើន។ ទិន្នផលបានខ្ពស់បំផុត នៅតាមភូមិមានដំណើរការខ្លាំង និងភូមិដែលមានប្រព័ន្ធស្រោចស្រពធម្មជាតិ រីឯភូមិមានដំណើរការបង្គួរ និងអន់ ជាទូទៅគ្មានសន្តិសុខស្បៀងទេ ។ ភូមិមានដំណើរការខ្លាំងក៏មានអន្តរាគមន៏ជួយអភិវឌ្ឍន៏ច្រើនជាងដែរ ដូចជា ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ហើយប្រព័ន្ធទឹកស្អាត/អនាម័យ ក៏ឃើញមានច្រើនជាងដែរ ។ សេវាថែទាំសុខភាព និងការអប់រំមានការរីកចំរើននៅគ្រប់ភូមិសិក្សា ប៉ុន្តែសហគមន៏ដែលនៅដាច់ស្រយាលជាង

មានស្ថានភាពសុខភាពអន់ជាង សេវាថែទាំសុខភាពមានគុណភាពមិនទៀងទាត់ ហើយកុមារនៅក្នុងគ្រួសារក្រីក្រជាងគេ ជាពិសេសក្មេងស្រី នៅតែមិនទាន់បានទទួលការអប់រំ ។

របកគំហើញជាទូទៅនេះបានបង្ហាញនៅកំរិតមួយថា កំនើននៅកម្ពុជាមិនទាន់មានលក្ខណៈរាប់បញ្ចូលទេ ហើយនៅកំរិតមួយទៀតបានបង្ហាញពីបញ្ហាដែលត្រូវខំដោះស្រាយឱ្យបានកាន់តែច្រើននៅថ្នាក់មូលដ្ឋាន។ ទោះបីជាទូទៅ ការសិក្សាបានបញ្ជាក់គាំទ្រដល់ការយល់ដឹងរបស់យើងអំពីអន្តរកម្មរវាងភាពក្រីក្រ និងកត្តាកំនត់ភាពក្រីក្រ មួយចំនួនក៏ពិតមែន ប៉ុន្តែវាក៏បានបំផុសបញ្ហាជាច្រើនដែលត្រូវធ្វើការវាយតំលៃដោយប្រុងប្រយ័ត្ន។ ដើម្បីឱ្យកាន់តែច្បាស់លាស់ថែមទៀត យើងត្រូវធានាឱ្យបានថា របកគំឃើញមិនរងឥទ្ធិពលពីចលនាធ្លាក់ចូល និងចាកផុតភាពក្រីក្រក្នុងរយៈពេលខ្លីទេ ដូច្នេះត្រូវធ្វើការសិក្សាមួយជុំថ្មីទៀត ។ ព័ត៌មានដែលទទួលបាន នឹងជួយអ្នកស្រាវជ្រាវឱ្យធ្វើវិភាគពីឌីណាមិកនៃភាពក្រីក្របានកាន់តែម៉ត់ចត់ និងលើកសំនើជំរើសគោលនយោបាយម៉ាក្រូ និងមីក្រូ កាន់តែច្បាស់លាស់ឡើង។ ជុំថ្មីនៃ MOPS ដែលមានឈ្មោះថា ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ កំពុងដំណើរការទៅមុខដោយ CDRI។ ការសិក្សានេះ នឹងផ្តល់ទិន្នន័យថ្មីៗ ដែលជួយឱ្យអ្នកស្រាវជ្រាវនៅ CDRI ធ្វើការតាមដានបានពេញលេញពីឌីណាមិកនៃភាពក្រីក្រនៅកម្ពុជា ក្នុងអំឡុងពេល ១៥ឆ្នាំចុងក្រោយនេះ ។

## ៥. សារៈសំខាន់នៃវិធីសាស្ត្រ MOPS

MOPS ជាវិធីថ្មីមួយសំរាប់សិក្សាពីភាពក្រីក្រក្នុងទូទាំងពិភពលោក ទោះបីការស្រាវជ្រាវហាក់ដូចមានការ ប្តូរទិសខ្លះ និងឃ្លាតមួយកំរិតចេញពីវិធីជាប្រពៃណីក្តី ប៉ុន្តែតាមពិតវិធីទាំងថ្មីទាំងចាស់វាបំពេញឱ្យគ្នាទៅវិញទៅមក ។ MOPS និង វិធីសាស្ត្រស្រដៀងគ្នាឯទៀតៗ បានសិក្សាកាន់តែជ្រៅពីមូលហេតុនៅកំរិតមីក្រូនៃភាពក្រីក្រ ដោយផ្តល់នូវព័ត៌មានដ៏ចាំបាច់សំរាប់ជួយកែតំរូវគោលនយោបាយម៉ាក្រូ ។

ក្រៅពីប្រទេសចិន និងឥណ្ឌាចេញ ការកាត់បន្ថយភាពក្រីក្រនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ មានសន្ទុះយឺតក្នុងពីរបីទសវត្សរ៍ចុងក្រោយនេះ ហើយវាផ្តល់គំនិតថា គោលនយោបាយនៅតាមប្រទេសនានាត្រូវតែកែតំរូវឡើងវិញ ។ MOPS និង ការសិក្សាប្រភេទនេះ ដែលពិនិត្យកាន់តែស៊ីជំរៅពីមូលហេតុនៃភាពក្រីក្រ នឹងជួយផ្តល់ព័ត៌មានសំរាប់ការងារនេះ ។ ចំណុចទន់ខ្សោយមួយចំនួនរបស់អ្នកក្រ តំរូវឱ្យពិនិត្យដិតដល់ពីការគ្រប់គ្រងភាពក្រីក្រនៅកំរិតមីក្រូ។ ចំណុចទន់ខ្សោយអាចជាប់ទាក់ទងនឹងបញ្ហាជនជាតិ យេនឌ័រ ទីតាំងមិនល្អ និងកត្តារចនាសម្ព័ន្ធ។ ក្នុងករណីបែបនេះ គោលនយោបាយម៉ាក្រូសំរាប់ការកាត់បន្ថយភាពក្រីក្រ ត្រូវគួបផ្សំជាមួយនឹងការកំនត់ទិសដៅឱ្យកាន់តែចំលើ ក្រុមអ្នកក្រីក្រ។ ការយល់ដឹងដែលទទួលបានពីការស្រាវជ្រាវបែបនេះ គួរដាក់បញ្ចូលក្នុងគោលនយោបាយម៉ាក្រូ ដើម្បីធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព សំរាប់មិនមែនត្រឹមតែពង្រីកឱកាសសេដ្ឋកិច្ចអោយដល់គ្រប់ៗគ្នានោះទេ ប៉ុន្តែសំរាប់ទាំងដោះស្រាយភាពក្រីក្រទៀតផង ។

## ៦. ការគួបផ្សំវិធីសាស្ត្រខុសៗគ្នា

កត្តាកំនត់ភាពក្រីក្រមានច្រើន និងមានអន្តរកម្មជាមួយភាពក្រីក្រ និងជាមួយកត្តាដូចគ្នាទៅវិញទៅមកស្មុគស្មាញណាស់ ធ្វើឱ្យការវិភាគក្នុងទីតាំងនីមួយៗជួបការលំបាក។ ដើម្បីយល់បានច្បាស់ពីភាពក្រីក្រនៅទីតាំងណាមួយ ហើយកសាងបានគោលនយោបាយដ៏សក្តិសិទ្ធិនិងអនុវត្តកើត ដើម្បីដោះស្រាយភាពក្រីក្រនោះ គេត្រូវប្រើវិធីសាស្ត្រច្រើនបែបយ៉ាង។ ព័ត៌មាន និងទិន្នន័យដែលទទួលបាន នឹងជួយឱ្យអ្នកស្រាវជ្រាវកសាងនូវគោលនយោបាយ ជារួម និងសំរាប់ទីតាំងនីមួយៗ កាន់តែត្រឹមត្រូវឡើង ។ វិធីនេះសមស្របណាស់សំរាប់ដោះស្រាយ ភាពក្រីក្រជាប់រហូត រឺកត្តាខាងទីតាំង/រចនាសម្ព័ន្ធផ្សេងៗដែលដើរតួសំខាន់នៅក្នុងស្ថានភាពក្រីក្រ ។

បញ្ហាពាក់ព័ន្ធមួយទៀតជាប់ទាក់ទងនឹងបច្ចេកទេសវិភាគដែលអនុវត្តលើព័ត៌មាន និងទិន្នន័យបានមកពីវិធីសាស្ត្រខុសៗគ្នា ។ ការសិក្សាម៉ាក្រូភាគច្រើនលើភាពក្រីក្រ ប្រើបច្ចេកទេសបែបបរិមាណក្នុងការវិភាគទិន្នន័យ រីឯការសិក្សាតូចៗជាទូទៅប្រើបច្ចេកទេសបែបគុណភាព ។ នេះជាវិស័យមួយទៀត ដែលគេមានលទ្ធភាពច្រើនណាស់ក្នុងការគួបផ្សំបច្ចេកទេសពីរ ដើម្បីកសាងគោលនយោបាយបានកាន់តែមានប្រសិទ្ធភាព និងសំបូរបែបឡើង។ ការសិក្សាពីឌីណាមិកនៃភាពក្រីក្រដែលកំពុងដំណើរការដោយ CDRI បានផ្តល់កំរងព័ត៌មាននិងទិន្នន័យបែបគុណភាព និងបរិមាណដ៏ធំៗជាច្រើនរួចមកហើយ ។ អ្នកស្រាវជ្រាវរំពឹងថា នឹងប្រើវិធីសាស្ត្រចំរុះក្នុងការសិក្សានេះ (ហៅថា Q-Squared[៩]) ដែលគួបផ្សំទាំងបច្ចេកទេសបែបគុណភាព និងបែបបរិមាណ ។

អត្ថបទពីរទៀតក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជាលេខនេះ នឹងពិភាក្សាពីវិធីសាស្ត្រខុសៗគ្នាសំរាប់វាស់វែង និងតាមដានភាពក្រីក្រនៅកម្ពុជា ។ អត្ថបទមួយ លើកពីបញ្ហាផ្សេងៗទាក់ទងនឹងវគ្គលើកក្រោយនៃ MOPS ហើយអត្ថបទមួយទៀត អធិប្បាយពីវិធីសាស្ត្រប្រើប្រាស់ក្នុងគំរោង IDPoor ដែលអនុវត្តដោយក្រសួងផែនការ ៕

### កំណត់សំគាល់

១. I. Fitzgerald & So S. (2007) *ការសិក្សាពីការចាកផុតភាពក្រីក្រ: និន្នាការខាងសុខមាលភាពរបស់សហគមន៍ និង ចលនាឈានឡើងរបស់គ្រួសារក្នុងភូមិចំនួន៩ នៅកម្ពុជា* (ភ្នំពេញ: CDRI) ។

២. ឧទាហរណ៍ សូមមើល B. Ballard (ed.) (2007), *យើងរស់នៅដោយក្តីព្រួយបារម្ភគ្រប់ពេលវេលា: ការវាយតំលៃពី ភាពក្រីក្រដោយមានការចូលរួមនៅទន្លេសាប* (ភ្នំពេញ: CDRI) និង ធនាគារពិភពលោក (២០០៧) ការបែងចែកវិបុលភាព (ភ្នំពេញ: ធនាគារពិភពលោក) ។

៣. CDRI (2007a) *របាយការណ៍អង្កេតមូលដ្ឋានលើការធ្វើប័ណ្ណកម្មសិទ្ធិដីនៅជនបទកម្ពុជា* (ភ្នំពេញ: CDRI) និង CDRI (2007b), *របាយការណ៍អង្កេតមូលដ្ឋានពីការធ្វើប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុងកម្ពុជា* (ភ្នំពេញ: CDRI) ។

៤. សេចក្តីលំអិតពីគំរោងនេះ មានចុះក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជាលេខនេះ។

៥. J. Weiss & H.A. Khan (ed.) (2006), *យុទ្ធសាស្ត្រភាពក្រីក្រនៅអាស៊ី: វិធីសាស្ត្រកំនើនបន្ថែមមួយ* (Cheltenham and Northampton, MA: Edward Elgar) ។

៦ គួរកត់សំគាល់ជាសំខាន់ថា តួលេខអំណាចទិញប៉ុនគ្នា (purchasing power parity) ដែលត្រឹមត្រូវជាងសំរាប់បរិបទនេះ វាខ្ពស់ជាងនេះច្រើនណាស់។

៧. សំរាប់តួលេខនេះ និង តួលេខដែលពាក់ព័ន្ធផ្សេងទៀត សូមមើលឯកសារ World Bank (2007) ។

៨. សំរាប់ព័ត៌មានលំអិតលើបញ្ហាទាំងនេះ សូមមើលឯកសារ Hossein Jalilian (2008) "សេចក្តីផ្តើម" *ក្នុងទស្សនាវដ្តីអភិវឌ្ឍន៍ប្រចាំឆ្នាំ* ២០០៧-២០០៨ (ភ្នំពេញ: CDRI)

៩. សំរាប់ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រនេះ សូមមើល R. Kanbur (ed.), Q-Squared: វិធីសាស្ត្របែបគុណភាព និងបរិមាណសំរាប់វាយតំលៃពីភាពក្រីក្រ (Washington, DC: Permanent Black) ។

# ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ៖ ឧបករណ៍តាមដានការកាត់បន្ថយភាពក្រីក្រ

*រៀបរៀងដោយលោក សូ សុវណ្ណារិទ្ធិ **

## សេចក្ដីផ្ដើម

វិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(វបសអ-CDRI) កំពុងធ្វើការសិក្សាពីឌីណាមិកនៃភាពក្រីក្រ (Poverty Dynamics Study: PDS)ដែលមានរយៈពេល២ឆ្នាំ (ឆ្នាំ២០០៨ និង ២០០៩)។[1] PDS បានធ្វើឡើងបន្តពី ការសិក្សាពីការចាកផុតភាពក្រីក្រ (Moving Out of Poverty: MOPS) ដែលជាផ្នែកមួយនៃការសិក្សាលើ ១៨ ប្រទេស របស់ធនាគារពិភពលោក ក្នុងអំឡុងឆ្នាំ២០០៤ និង ២០០៥។ កម្ពុជាជាប្រទេសតែមួយគត់ក្នុងការសិក្សានេះ ដែលបានបន្តប្រមូលទិន្នន័យតាមបណ្ដោយពេល (longitudinal) និងជាលក្ខណៈក្រុម សំរាប់តាមដាន និងវិភាគលើគោលនយោបាយជាតិ។

ការសិក្សា PDS ជាឧបករណ៍សំខាន់មួយសំរាប់តាមដានភាពក្រីក្រ ដែលមាន ការអនុវត្តផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងការកំនត់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្របន្តពីនេះទៀតនៅឆ្នាំ២០១០ ។ ការសិក្សានេះ បានរចនារៀបចំជាពិសេសដើម្បីបង្ហាញពីទស្សនវិស័យក្នុងមូលដ្ឋាន និងទៅតាមបណ្ដោយពេល លើនិន្នាការនៃ ភាពក្រីក្រនៅកម្ពុជា ។ និន្នាការទាំងនេះមានបង្ហាញក្នុង អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ១៩៩៣/៩៤ ១៩៩៧ និង ២០០៤, ស្ថានភាពភាពក្រីក្រនៅកម្ពុជាឆ្នាំ១៩៩៣ ១៩៩៧ និង ២០០៤ កសាងឡើងដោយ វិទ្យាស្ថានជាតិស្ថិតិ (NIS), និង អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាចំនួនពីរ ធ្វើនៅ ឆ្នាំ២០០០ និង ២០០៥ (NIPH *et al.* 2006; NIS *et al.* 2001 )។ ការវិភាគបន្ថែមទៀតលើនិន្នាការភាពក្រីក្រ និងវិសមភាព មានធ្វើឡើងក្នុងឯកសារ World Bank (2006) និង World Bank (2007)។ របាយការណ៍សិក្សាផ្សេងៗទៀត រួមមាន Ballard (2007), CDRI (2007a & 2007b) និង IRL (2007)។

PDS បានរចនារៀបចំឡើង ដើម្បីប្រើទិន្នន័យតាមបណ្ដោយពេលទាំងបែបបរិមាណនិងគុណភាព សំដៅរកមើលពី របៀបអាចជំរុញកំណើនដែលមានលក្ខណៈរាប់បញ្ចូល សំរាប់កាត់បន្ថយភាពក្រីក្រ និងវិសមភាព ។ ការសិក្សានេះ ធ្វើតេស្តសាកល្បង និងព្យាយាមពន្យល់ពីបទពិសោធន៍នៅមូលដ្ឋាន រួចហើយធ្វើការបញ្ជាក់គាំទ្រ រឺក៏ចោទសំនួរ អំពីនិន្នាការជាតិ ដោយផ្អែកលើបទពិសោធន៍របស់ប្រជាជនដែលបានចាកផុត រឺធ្លាក់ចូលក្នុងភាពក្រីក្រ។

ការសិក្សានៅឆ្នាំ២០០៤/០៥ និង អង្កេតពីរដែលធ្វើឡើងនៅឆ្នាំ២០០១ និង ២០០៤/០៥ អាចឱ្យយើងបានដឹងពី មូលហេតុ និង ចលនានៃការចាកផុត និងធ្លាក់ចូលក្នុងភាពក្រីក្រ ។ ប៉ុន្តែការសិក្សានេះ មិនអាចវាយតំលៃបានទេថា តើចលនានេះវាបណ្ដោះអាសន្នរឺយ៉ាងណា តើគ្រួសារមួយចំនួនដែលឡើងធូរធារអាចចុះក្រីក្រវិញដែររឺទេ តើគ្រួសារដែលធ្លាក់ខ្លួនក្រនឹងនៅតែក្ររហូត រឺក៏អាចធូរធារឡើងវិញ ។ ការសិក្សានេះក៏មិនអាចវាយតំលៃដែរថា តើឌីណាមិកនៃភាពក្រីក្រដែលបានសង្កេតឃើញពីឆ្នាំ២០០១ ដល់ ២០០៤/០៥ (ពេលដែលកម្ពុជាជួប គ្រោះទឹកជំនន់ និងរាំងស្ងួតច្រើនឆ្នាំជាប់ៗគ្នា) វាខុសពីធម្មតា រឺក៏ស្របគ្នានឹងនិន្នាការយូរអង្វែង។ PDS នឹងស្វែងរកចំលើយលើសំនួរទាំងនេះ ។

សំនួរស្រាវជ្រាវសំខាន់ៗដែលគំរោងរយៈពីរឆ្នាំនេះ ត្រូវប្រឹងប្រែងស្វែងរកចំលើយ មានដូចខាងក្រោម៖

- តើចលនាចាកផុតពីភាពក្រីក្រមានលក្ខណៈជាប់លាប់ប៉ុណ្ណា? តើចលនាប៉ុណ្ណាដែលអាចហៅថា "វិលចុះឡើង" (គ្រួសារធូរធារឡើង រួចចុះក្រវិញម្ដងទៀត) និងដែលមិនមែនជា ចលនាមានចីរភាព ។
- តើនិន្នាការសហគមន៍(កំនើនរឺការធ្លាក់ចុះ) វាជាលទ្ធផលនៃកត្តារយៈពេលខ្លី (ដូចជា ទឹកជំនន់ និង រាំងស្ងួត) រឺក៏ជានិន្នាការរយៈពេលវែង?
- តើកត្តាសំខាន់ៗខាងគ្រួសារ និងភូមិ ដែលបានកំនត់ឃើញក្នុងការសិក្សាឆ្នាំ២០០៤/២០០៥ នៅតែលេចធ្លោដដែល រឺយ៉ាងណា? តើមានដែររឺទេនូវកត្តាថ្មីៗដែលមិនបានកំនត់ឃើញនៅឆ្នាំ២០០៤/០៥?
- តើនិន្នាការ និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជះឥទ្ធិពលយ៉ាងណាទៅលើសហគមន៍ និងគ្រួសារ? តើភូមិ និងក្រុមចលនាផ្សេងៗ អាចទទួលបានច្រើនប៉ុណ្ណានូវឱកាសល្អ និងផលចំណេញខាងសេដ្ឋកិច្ច អំពីកំនើន? តើវិសមភាព នៅជនបទកើនឡើង រឺក៏ថយចុះ?
- សំរាប់ភូមិ និងគ្រួសារនានា តើយុទ្ធសាស្ត្រសំរាប់ធ្វើចំរុះកម្មមុខចំណូលអ្វីដែលមានប្រសិទ្ធភាពបំផុត សំរាប់ជួយទ្រទ្រង់ដល់ចលនាឈានឡើង (ឧ. កំណើនផលិតភាព ការបង្កើនប្រភពចំនូល ការធ្វើចំនាកស្រុក)? តើការថយចុះធនធានទ្រព្យរួម និង គោលនយោបាយព្រៃឈើនិងនេសាទ មានផលប៉ះពាល់ អ្វីខ្លះដល់និន្នាការនៃភាពក្រីក្រ និងការចិញ្ចឹមជីវិត?
- តើស្ត្រី និងបុរស មានបទពិសោធន៍ខុសគ្នាយ៉ាងណា ទាក់ទិននឹងភាពក្រីក្រ កំនើនសេដ្ឋកិច្ច និងចលនាឈានឡើង? តើស្ត្រី និង បុរស បានចូលរួមចំនែករៀងៗខ្លួនអ្វីខ្លះដល់ប្រាក់ចំនូល និងផលិតភាពរបស់គ្រួសារ? តើការចូលរួមចំនែកខុសពីគ្នានេះ អាចប្រៀបធៀបយ៉ាងណាបានទៅនឹង ផលប្រយោជន៍ដែលពួកគេបានទទួល?

ការពិភាក្សា និង វិភាគទិន្នន័យដែលទទួលបានពីការសិក្សាបន្តពី MOPS នេះអាចជួយបំភ្លឺពីឌីណាមិកនៃ ភាពក្រីក្រ។ លទ្ធផលស្រាវជ្រាវ នឹងជួយឱ្យអ្នកកសាងគោលនយោបាយកម្ពុជាកើនការយល់ដឹង កំនត់គោលដៅបានកាន់តែច្បាស់ និងធ្វើអន្តរាគមន៍បានកាន់តែប្រសើរ ។

## ១. ក្របខ័ណ្ឌគោលគំនិត

ខាងក្រោមនេះ ជាសម្មតិកម្មស្រាវជ្រាវដែលយើងត្រូវស្វែងរកចំលើយ ។ ការបង្កើនកំនើនដើម្បីកាត់បន្ថយវិសមភាព និងភាពក្រីក្រ គឺជាក្របខ័ណ្ឌស្រាវជ្រាវសំរាប់ពិនិត្យលើសំនួរស្រាវជ្រាវ និងគោលនយោបាយសំខាន់ៗ ។ ក្របខ័ណ្ឌនេះបានរចនារៀបចំឡើង ដើម្បីធ្វើជាមូលដ្ឋានសំរាប់ធ្វើតេស្តសាកល្បង នូវផែនការផ្សេងៗដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និងផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ ព្រមទាំង បង្កើតឯកសារខាងទ្រឹស្តីលើប្រធានបទនេះ ។ ការខិតខំបង្កើនការចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិ និងសកលភាវូបនីយកម្ម អាចមានផលប៉ះពាល់ផ្ទាល់ និងប្រយោលលើភាពក្រីក្រ តាមរយៈការបង្កើន សកម្មភាពសេដ្ឋកិច្ច ការងារ និងកិរិតសុខមាលភាព ។ តំរូវការកត្តាផលិតកម្មផ្សេងៗដូចជា ដីធ្លី ពលកម្ម និងមូលធនហិរញ្ញវត្ថុ ទំនងជានឹងកើនឡើងទន្ទឹមគ្នានឹងកំនើនសកម្មភាព

* លោក សូ សុវណ្ណារិទ្ធិ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។ អត្ថបទនេះ ផ្អែកទៅលើការសិក្សាពីការចាកផុតភាពក្រីក្រ (MOPS) របស់ CDRI កាលពីមុន

សេដ្ឋកិច្ច ហើយផ្ដល់ផលប្រយោជន៍ផ្ទាល់ដល់អ្នកក្រ ។ ម្យ៉ាងទៀត អ្នកក្រមានឱកាសកាន់តែប្រសើរដើម្បីទទួលបានផលប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលកាន់តែច្រើនពីអន្តរាគមន៍ខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមកិច្ច ។ ប៉ុន្តែឯកសារជាតិ និងអន្តរជាតិសព្វថ្ងៃបង្ហាញថា កំណើនមិនអាចគ្រប់គ្រាន់សំរាប់កាត់បន្ថយភាពក្រីក្រទេ បើសិនគ្មាន កំណែលំអខាងអភិបាលកិច្ច និងការបង្កើតស្ថាប័នសមស្រប ជាពិសេសដើម្បីធានាកម្មសិទ្ធិអចលនទ្រព្យ និង ពង្រឹងនីតិរដ្ឋ។ ស្ថិរភាពសេដ្ឋកិច្ច នយោបាយ និងសង្គមសំខាន់ខ្លាំងណាស់សំរាប់បង្កើតបរិយាកាសល្អជួយជំរុញ វិនិយោគ និងការហ៊ានប្រថុយនឹងហានិភ័យដែលចាំបាច់បំផុតដើម្បីញ៉ាំងឱ្យមានកំណើនខ្ពស់ប្រកបដោយចីរភាព។

ការសិក្សាក៏មានគោលដៅធំទូលាយនៃការកសាងចំនេះដឹង និងជំនាញខាងវិភាគរបស់អ្នកស្រាវជ្រាវនៅ CDRI ដែលចូលរួមក្នុងគំរោងនេះ ។ ខុសប្លែកពីការសិក្សានៅឆ្នាំ២០០៤/០៥ ឯកទេសជំនាញរបស់អ្នកស្រាវជ្រាវម្នាក់ៗនឹងត្រូវប្រើប្រាស់ និងពង្រឹងតាមរយៈការតាមដានពីប្រសិទ្ធភាពនៃគោលនយោបាយរដ្ឋាភិបាលក្នុងការពន្លឿនកំណើន ដើម្បីកាត់បន្ថយភាពក្រីក្រ ។

ការរកឃើញរបស់ MOPS ដែលបានផ្ដល់គំនិតយ៉ាងច្រើនដល់ របាយការណ៍វាយតំលៃភាពក្រីក្រនិងវិសមភាពរបស់ធនាគារពិភពលោក នឹងត្រូវកែសំរួល និងផ្ទៀងផ្ទាត់យោងតាមកស្តុតាងផ្សេងៗដែលទទួលបានពីកំណត់ត្រា និងការវិភាគតាមបណ្ដោយពេលរបស់ PDS ។ ការស្រាវជ្រាវនេះ គួបផ្សំនឹងទិន្នន័យជាក្រុមដែលប្រមូលបាននៅឆ្នាំ ២០០១ និង ២០០៤/០៥ នឹងជួយបង្កើនការយល់ដឹងពីទំនាក់ទំនងដ៏ជ្រាលជ្រៅរវាង កំណើន វិសមភាព និងការកាត់បន្ថយភាពក្រីក្រ ។ អ្នកស្រាវជ្រាវរបស់ CDRI នឹងអាចកំនត់បានកាន់តែពេញលេញថា តើក្នុងករណីសិក្សាទាំងនេះ មានកត្តាជំរុញកំណើនដែរឬទេ ។ កត្តាសំខាន់ៗសំរាប់កំណើន មានជាអាទិ៍ វិនិយោគលើមូលធនរូបវ័ន្តនិងធនធានមនុស្ស វិនិយោគខាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមកិច្ច ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ក្របខ័ណ្ឌអភិបាលកិច្ចនិងស្ថាប័ន និងស្ថិរភាពសេដ្ឋកិច្ច នយោបាយ នឹងសង្គម ។ ក្រៅពីការកំនត់អត្តសញ្ញាណអ្នកក្រ និងកត្តាផ្សេងៗនៃឌីណាមិកភាពក្រីក្រ PDS ក៏ខិតខំពង្រីកការយល់ដឹងខាងគោលនយោបាយស្ដីពី វិធីសំរាប់ញ៉ាំងឱ្យកំណើនមានលក្ខណៈរាប់បញ្ចូលដែរ ។ លទ្ធផលរកឃើញនឹងជួយបំភ្លឺ កំនៃទំរង់គោលនយោបាយរដ្ឋាភិបាលនាពេលថ្មីៗ តួនាទីរបស់វិស័យឯកជនក្នុងការអភិវឌ្ឍជនបទ/ការកាត់បន្ថយភាពក្រីក្រ ព្រមទាំងជួយបង្ហាញពីទិសដៅគោលនយោបាយដើម្បីសំរេចបានគោលដៅកាត់បន្ថយភាពក្រីក្រឱ្យបាន ៥០% នៅ ត្រឹមឆ្នាំ២០១៥ ។ នៅកម្ពុជា មិនទាន់មានចំណងទាក់ទងរឹងមាំល្អទេ រវាងជោគជ័យម៉ាក្រូសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ (Fitzgerald & So 2007; Ballard 2007; CDRI 2007b) ។

## ២. គោលដៅនៃការស្រាវជ្រាវ

PDS មានគោលដៅផ្ដល់ព័ត៌មានជូនអ្នកកសាងគោលនយោបាយ ដោយខិតខំស្វែងយល់កាន់តែស៊ីជំរៅពី ឌីណាមិក មូលហេតុ និងនិន្នាការនៃភាពក្រីក្រ តាមរយៈការវិភាគទិន្នន័យក្រុមដែលបានពី ៩ភូមិសិក្សា។ ការសិក្សា នឹងបន្តប្រើវិធីសាស្ត្របែបបរិមាណ និងបែបគុណភាព ។ ដើម្បីរក្សាឲ្យតទិន្នន័យក្រុមគ្រួសារដដែលនឹងត្រូវធ្វើអង្កេតឡើងវិញនៅឆ្នាំ២០០៨ ហើយសំនួរគ្រួសារជាច្រើន ដែលមិនបានសួរក្នុង MOPS ឆ្នាំ២០០៤/០៥ នឹងត្រូវដាក់បញ្ចូលក្នុងការសិក្សាលើកនេះដើម្បីឱ្យមានទិន្នន័យអាចប្រៀបធៀបគ្នាបាន។ MOPS ប្រើស្ថិតិពិពណ៌នា ដើម្បីវិភាគលើនិន្នាការសហគមន៍ និងកត្តានានាដែលជះឥទ្ធិពលដល់ចលនាគ្រួសារ ។ ក្នុងការសិក្សានេះ មានប្រើការវាស់វែងស្ថិតិកាន់តែទំនើបដើម្បីវិភាគលើបទពិសោធន៍ភាពក្រីក្រ និងស្វែងយល់ពីនិន្នាការសហគមន៍និងគ្រួសារ ព្រមទាំងឌីណាមិកនៃភាពក្រីក្រ ។ ការសិក្សាលើកនេះនឹងប្រឹងប្រែងបំបែកកត្តាចលនាសំខាន់ៗ ជាអត្ថបទសង្ខេបគោលនយោបាយខ្លីៗ និងប្រធានបទមួយចំនួន សំរាប់ធ្វើការផ្សព្វផ្សាយ ។

វិធីសាស្ត្របែបគុណភាព នឹងមានប្រើក្រុមគោលដៅ និងបទសំភាសន៍ពាក់កណ្ដាលរៀបរយ ដើម្បីធ្វើការគណនាលើទិន្នន័យបែបបរិមាណដែលប្រមូលបានពីអង្កេតគ្រួសារ ព្រមទាំងសិក្សាពីទិដ្ឋភាព និងបញ្ហានានាដែលមិនអាចសិក្សាបានល្អតាមវិធីសាស្ត្របែបបរិមាណ ដូចជា អភិបាលកិច្ច ទំនុកចិត្តលើស្ថាប័នសាធារណៈ សុវត្ថិភាព និងសន្តិសុខ ។ លើសពីនេះ ការសិក្សាឆ្នាំ២០០៨ នឹងផ្ដល់ឱកាសសំរាប់ធ្វើវិភាគកាន់តែស៊ីជំរៅលើបញ្ហានានាដែលផុសឡើង ដោយប្រៀបធៀបនឹងការសិក្សានៅឆ្នាំ២០០៤/០៥ និងការសិក្សាផ្សេងៗទៀតរបស់ CDRI ស្ដីពីភាពក្រីក្រ និងការចិញ្ចឹមជីវិត ។ ការសិក្សានឹងពិនិត្យលំអិតថែមទៀតពីវិសមភាពរវាងភូមិជនបទនិង គ្រួសារនានា តួនាទីនៃឥណទាន ចំនាកស្រុកក្នុងចលនាចាកផុតពីបញ្ហាភាពក្រីក្រ និងបញ្ហាផ្សេងៗខាងវិសមភាព ដូចជា ការរួមចំនែករបស់ស្ត្រី និងបុរស-នារីវ័យក្មេង ដល់ប្រាក់ចំណូលរបស់គ្រួសារ និងផលប្រយោជន៍ដែល ពួកគេទទួលបាន ។

ជាបន្ថែមពីលើការចងក្រងលទ្ធផលរកឃើញជារបាយការណ៍សំរេចមួយ អ្នកស្រាវជ្រាវនឹងបំបែករបកគំហើញ ជាឯកសារសង្ខេបគោលនយោបាយមួយចំនួន ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងតំរូវការព័ត៌មានពីសំណាក់អ្នកកសាងគោលនយោបាយ និងអ្នកធ្វើសេចក្ដីសំរេចចិត្ត។ ក្នុងនេះបានកំនត់ចេញជាប្រធានបទសំខាន់ៗ ចំនួន ៥ សំរាប់ពិនិត្យអង្កេតស៊ីជំរៅដើម្បីបង្កើតអត្ថបទសង្ខេបគោលនយោបាយ ដូចតទៅ :

១. ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារទៅលើ សន្តិសុខស្បៀង ផលិតកម្មកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ
២. កម្មសិទ្ធិដីធ្លី សុវត្ថិភាពកាន់កាប់ដី និងការប្រើប្រាស់ដីប្រកបដោយផលិតភាព
៣. ការអភិវឌ្ឍមីក្រូ-ហិរញ្ញវត្ថុ កំណើន និង ការកាត់បន្ថយភាពក្រីក្រ
៤. វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ: ការកែលំអផ្លូវថ្នល់ ផលិតកម្មកសិកម្ម ទីផ្សារ និងការធ្វើពិពិធកម្មប្រភពចំនូល
៥. ទីផ្សារពលកម្ម: ចំនាកស្រុក កំណើន និងការកាត់បន្ថយភាពក្រីក្រ ។

ប្រធានបទទាំងនេះ បានជ្រើសរើសឡើងដោយផ្អែកលើ អាទិភាពដែលបានកំនត់នៅពេលចុះពិនិត្យភូមិសិក្សាទាំង ៩ ក្នុងចន្លោះពេលពីថ្ងៃទី ២២ មករា ដល់ ៦ កុម្ភៈ ២០០៨ ដើម្បីកំនត់ពីបញ្ហា និងនិន្នាការក្នុងសហគមន៍ ព្រមទាំង ផ្ទៀងផ្ទាត់ពី នីតិវិធីយកគំរូតាង ការប្រមូលទិន្នន័យ ការវាស់វែង និងក្របខ័ណ្ឌធ្វើវិភាគ ។ ប្រធានបទនានាបានទទួលការអនុម័តក្នុងកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងមួយនៅថ្ងៃទី១៦ ឧសភា ២០០៨។ ការពិភាក្សាលំអិតពីមូលដ្ឋានទ្រឹស្តី និងបទពិសោធន៍ជាក់ស្តែង ដែលបានបង្កើតជាសម្ពតិកម្មនិងសំនួរស្រាវជ្រាវទាក់ទងនឹងកម្ពុជា មានចុះក្នុងវេបសាយ http://www.cdri.org.kh/under "Major Projects" ។ យោងតាមបទពិសោធន៍អនុវត្ត MOPS គេត្រូវធ្វើការសិក្សាឯកសារយ៉ាងល្អមួយ មុននឹងដំណើរការស្រាវជ្រាវលំអិតថែមទៀតលើប្រធានបទទាំង ៥ នេះ ។

តួយ៉ាងជាក់ស្តែង ចំពោះប្រធានបទទី១ ការឡើងថ្លៃម្ហូបអាហារទំនងជាធ្វើអោយភាពក្រីក្ររីករាលដាល និងធ្លាក់ធ្ងន់ធ្ងរមួយកំរិតទៀត ។ ប៉ុន្តែក្នុងរយៈពេលវែង សំរាប់ប្រទេសមួយដែលមានសក្តានុពលអាចសំរេចបាន អតិរេកយ៉ាងច្រើនៗនៃផលិតផលកសិកម្ម ផលប៉ះពាល់ទំនងជាមានលក្ខណៈវិជ្ជមាន

អោយតែគេបានអនុវត្ត វិធានការធានាឱ្យមានការប្រើប្រាស់ធនធាននានាប្រកបដោយប្រសិទ្ធិភាពខ្ពស់ ជាពិសេសដីធ្លី ។

ក្នុងអំឡុងពេលធ្វើទស្សនកិច្ចដំបូង នៅខែកុម្ភៈ ២០០៨ ការឡើងថ្លៃម្ហូបអាហារ ជាការបារម្ភខ្លាំងជាងគេក្នុងជួរអ្នកដឹកនាំនៅមូលដ្ឋាន និងក្នុងចំណោមអ្នកកសាងគោលនយោបាយ នឹងអ្នកសំរេចចិត្ត។ ដូច្នេះជាការសំខាន់ដែលត្រូវសិក្សាពីកត្តារួមចំនែកដល់ការឡើងថ្លៃម្ហូបអាហារ ហើយប្រសិនបើម្ហូបអាហារនៅតែមានថ្លៃខ្ពស់ គេត្រូវសិក្សាពីផលប៉ះពាល់ដល់កំនើនវិសមភាព និងការកាត់បន្ថយភាពក្រីក្រ ។ យោងតាមប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ មូលហេតុចំបងនៃការឡើងថ្លៃម្ហូបអាហារយ៉ាងខ្ពស់ គឺ ១) កំនើនការប្រើប្រាស់របស់ប្រជាជនថ្នាក់កណ្ដាលនៅប្រទេសចិន និងឥណ្ឌា ២) គ្រោះធម្មជាតិ និងគ្រោះមហន្តរាយបង្កដោយមនុស្ស និង ៣) ការឡើងថ្លៃប្រេង និងការធ្លាក់ថ្លៃប្រាក់ដុល្លារUS ។ សំនួរដ៏សំខាន់មួយគឺ តើកម្ពុជាអាចទាញយកផលចំណេញបានទេពីបាតុភូតសកលបែបនេះ ដើម្បីបង្កើនផលិតភាព និងចំរុះកម្មកសិកម្ម ។

ចំពោះបាតុភូតសកលខាងលើនេះ គេឃើញមានមតិទាំងវិជ្ជមាន និងអវិជ្ជមាន ដែលអាចស្រាវជ្រាវ និងពន្យល់បំភ្លឺដោយប្រើទិន្នន័យដែល CDRI ប្រមូលបាននៅឆ្នាំ២០០១, ២០០៤/០៥ និង ២០០៨ ។ ទីមួយ ប្រសិនបើម្ហូបអាហារនៅតែមានថ្លៃខ្ពស់ កម្ពុជាអាចទទួលបានឱកាសមាសពីរសំរាប់: ១) ការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីកាន់តែមានប្រសិទ្ធភាព ដើម្បីបង្កើនផលិតកម្ម និងចំរុះកម្មកសិកម្ម និង ២) ការទទួលបានផលចំនេញខ្ពស់ពីតំរូវការបិតថេរនូវទំនិញកសិកម្ម ។ ប្រសិនបើវាពិតដូច្នេះមែន ការឡើងថ្លៃម្ហូបអាហារក៏អាចទាក់ទាញវិនិយោគលើបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិតថ្មីខាងកសិកម្ម ដែលអាចបង្កើតការងារសំរាប់អ្នកក្រនៅជនបទ និងនាំឱ្យមានការបែងចែកប្រាក់ចំនូលកាន់តែប្រសើរ។ ផលចំនេញទទួលបានពីកំណើនផលិតកម្មកសិកម្ម និងទីផ្សារ អាចជួយឱ្យកម្ពុជាសំរេចបានកំនើនកាន់តែលឿន ព្រមទាំងការបែងចែកប្រាក់ចំនូល និងការកាត់បន្ថយភាពក្រីក្រកាន់តែប្រសើរ ។

ចំពោះឥទ្ធិពលអវិជ្ជមានវិញ ក្នុងរយៈពេលខ្លីនិងមធ្យម ម្ហូបអាហារនិងប្រេងមានថ្លៃខ្ពស់ អាចពន្យឺតការកាត់បន្ថយភាពក្រីក្រ ព្រមទាំងអាចធ្វើឱ្យភាពក្រីក្ររីករាលដាល និងកាន់តែធ្ងន់ធ្ងរថែមទៀត ។ ផលប្រយោជន៏ សំរាប់ផលិតកម្មកសិកម្មអាចមានតិចតួចបំផុត ហើយស្ថានភាពអំណោយផលក៏កាន់តែមានតិចសំរាប់បណ្ដាអាជីវកម្មខាងកសិកម្ម។ ដោយឡែក ស្ថានភាពអាចមិនអំណោយផលទេសំរាប់ការកែលំអបច្ចេសទេសកសិកម្ម នៅក្នុងបរិយាកាសនៃហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ ការគាំទ្រទន់ខ្សោយខាងស្ថាប័ន និងចំនាយប្រតិបត្តិការខ្ពស់ សំរាប់ពាណិជ្ជកម្មផលិតផលកសិកម្ម។ សម្មតិកម្មនេះអាចសមស្របខ្លាំងសំរាប់កម្ពុជាដែលត្រូវនាំចូល ធាតុចូលកសិកម្មភាគច្រើន ដូចជាជី និង ពូជដំណាំមានទិន្នផលខ្ពស់ ជាដើម ។ សព្វថ្ងៃនេះហេដ្ឋារចនាសម្ព័ន្ធកំពុងតែអភិវឌ្ឍឡើងក៏ពិតមែន ប៉ុន្តែកម្ពុជាដើរយឺតជាងគេឆ្ងាយណាស់បើធៀបនឹង ប្រទេសឯទៀតដែលមានសក្ដានុពលជំរុញកំនើននាំមុខដោយកសិកម្ម ។ ថ្លៃប្រេងខ្ពស់អាចធ្វើឱ្យឡើងថ្លៃធាតុចូលកសិកម្ម និងកាត់បន្ថយអត្រាចំនេញលើផលិតផល បើសិនផលិតផលឡើងថ្លៃយឺតជាង។ ថ្លៃប្រេងខ្ពស់ក៏អាចបង្កើនថ្លៃទំនិញប្រើប្រាស់ និងបង្កើនថ្លៃទ្រទ្រង់ជីវភាពនៅជនបទក្នុងកំរិតមួយដែលមិនអាចប៉ះប៉ូវបានដោយ ផលចំនេញតិចតួចបានមកពីផលិតកម្ម និងប្រាក់ចំនូលលើការលក់ពលកម្មកសិកម្ម ។ ការគួបផ្សំផលប៉ះពាល់ទាំងនេះ អាចធ្វើឱ្យសន្តិសុខស្បៀងកាន់តែយ៉ាប់យ៉ឺន ភាពក្រីក្រកាន់តែមានច្រើន កំណើនភាពគ្មានដីធ្លីកាន់តែស្ទុះលឿន ។ អ្នកក្រគ្មានដីដែលត្រូវទិញម្ហូបអាហារពីគេ អាចជួបអសន្តិសុខស្បៀង ។ កំណើនចំនាយលើម្ហូបអាហារ បានន័យថាអ្នកក្រមានប្រាក់កាន់តែតិចសំរាប់ចំនាយលើការសិក្សារបស់កូន ដូច្នេះពួកគេមិនអាចចាប់យកឱកាសល្អដើម្បីចាកផុតពីភាពក្រីក្រទេ ។ តើកម្ពុជាត្រូវធ្វើយ៉ាងណាដើម្បីជំនះលើបញ្ហាប្រឈមទាំងនេះ និងទាញយកផលចំណេញពីការឡើងថ្លៃម្ហូបអាហារ?

សំនួរទាំងឡាយដូចខាងលើអាចសិក្សាស្រាវជ្រាវ និងបកស្រាយបំភ្លឺដោយប្រើទិន្នន័យបានមកពីអង្កេតគ្រួសារនិងអង្កេតថ្លៃទំនិញកាលពីលើកមុនៗ ។ អង្កេតគ្រួសារផ្ដល់ទិន្នន័យស្ដីពី ១) កម្មសិទ្ធិដី លំនាំប្រើប្រាស់ដី ផលិតភាពដី និងការលក់ដី, ២) អ្នកទិញ និងអ្នកលក់សុទ្ធនូវស្រូវអង្ករ ៣) ថ្លៃផលិតផលកសិកម្មនៅទីផ្សារក្នុងភូមិ, ៤) ចំនូល និងចំនាយ, ៥) ជំរើសការងារ និង ៦) អន្តរាគមន៏អភិវឌ្ឍន៏ និងការទទួលបានព័ត៌មាន។ អង្កេតថ្លៃ បានផ្ដល់កំរិតថ្លៃនៃទំនិញប្រើប្រាស់ធម្មតាជាអាហារ និង មិនមែនអាហារ ចំនួន ១០៦មុខ នៅតាមទីផ្សារក្នុងភូមិ ស្រុក និង ខេត្ត ។

## ៣. ការតាមដានផលប៉ះពាល់ និងវិធីសាស្ត្រវាយតំលៃ

ព្រមជាមួយនឹងទិន្នន័យជាក្រុម បានមកពីសំភាសន៏គ្រួសារនៅឆ្នាំ១៩៩៦, ២០០១, ២០០៤/០៥ និង២០០៨ នឹងមានការពិនិត្យអង្កេតយ៉ាងល្អិតល្អន់លើប្រធានបទស្រាវជ្រាវទាំង ៥ តាមរយៈ បទសំភាសន៏ពាក់កណ្ដាល រៀបរយ និងការពិភាក្សាតាមក្រុមគោលដៅ នៅខែកញ្ញា-តុលា ២០០៨ ។ MOPS បានបង្ហាញថា ប្រជាជនជនបទមានសមត្ថភាពខុសៗគ្នា ដើម្បីទាញយកផលចំណេញពីឱកាសល្អដែលផុសចេញពីការអភិវឌ្ឍ និងកំនើន ។ អន្តរាគមន៏គោលនយោបាយតែម្យ៉ាង មិនអាចជួយអ្នកក្រ អ្នកមិនក្រ បុរស/នារី ទាំងអស់បានទេ ប្រសិនបើអន្តរាគមន៏នោះមិនបានដោះស្រាយកំហិត និងកសាងកំលាំងឱ្យពួកគេ ដើម្បីឱ្យពួកគេបានចូលរួមនៅក្នុង កំនើន និងការអភិវឌ្ឍ ។

កន្លងមកមានការជជែកវែកញែកក្ដៅគគុកពីវិធីតាមដាន និងវាយតំលៃដ៏សមស្រប សំរាប់វាស់វែងពីផលប៉ះពាល់នៃ ការធ្វើអន្តរាគមន៏ ។ ការវាយតំលៃផលប៉ះពាល់ ជារឿយៗផ្ដោតលើលទ្ធផលចុងក្រោយលើសុខមាលភាព មិនមែនលើតែលទ្ធផលគំរោង រឺក្របខ័ណ្ឌនៃគោលគំនិត និងការអនុវត្តនោះទេ។ ដោយបានយកមតិទាំងនេះមកពិចារណា PDS នឹងឆ្លៀតប្រើប្រាស់ទិន្ន័យបែបបរិមាណនៃគ្រួសារជាក្រុម និងឆ្លងវិស័យ ដែលបានពីអង្កេតនៅពេលខុសៗគ្នា ដើម្បីកំនត់ពីអ្នកបានទទួលផល និងអ្នកមិនបានទទួលផលពីអន្តរាគមន៏ (រឺប្រធានបទស្រាវជ្រាវសំខាន់ៗទាំង ៥) និងការប្រែប្រួលខាងសុខមាលភាព និងការកាត់បន្ថយភាពក្រីក្រក្នុងភូមិសិក្សា ។ អថេរអាចវាស់វែងបានសំខាន់ៗ សំរាប់ការសិក្សានេះ គឺមានបំរែបំរួលក្នុងការប្រើប្រាស់ប្រាក់ចំនូល ទ្រព្យសកម្ម មានផលិតភាពនិងគ្មានផលិតភាព ផលិតភាពដី និងការទទួលបានសេវាកម្មសង្គមផ្សេងៗ ។ ម្យ៉ាងទៀត អថេរការប្រើប្រាស់ នឹងយកមកប្រើដើម្បីកំនត់អ្នកក្រ និងអ្នកមិនក្រ ព្រមទាំង ចលនាគ្រួសារធៀបនឹងនិន្នាការសហគមន៏ ។

ដោយគួបផ្សំនឹងទិន្នន័យសិក្សាតាមបណ្ដោយពេល ការពិភាក្សាតាមក្រុមគោលដៅ និងបទសំភាសន៏ពាក់កណ្ដាលរៀបរយ គួរតែអាចឱ្យគេធ្វើវិភាគស៊ីជំរៅពីបែបបទ និងមូលហេតុដែលអ្នកក្រ អ្នកមិនក្រ ក្រុមមានចលនាផ្សេងៗ ស្ត្រី និងបុរស បានទទួលផលប្រយោជន៏ពីអន្តរាគមន៏ រឺនិន្នាការសហគមន៏នាបច្ចុប្បន្ន។ បញ្ហាប្រឈមចំបងក្នុងការវាយតំលៃពីផលប៉ះពាល់ គឺការកំនត់ពីអ្វីដែលកើតឡើងជាក់ស្ដែង នឹង អ្វីដែលមិនត្រូវកើតឡើងបើសិនគ្មានអន្តរាគមន៏ ។ បញ្ហានេះក៏ជាកំហិតមួយសំរាប់ PDS ដែរ ដោយសារកង្វះដំណែលនៃការរចនារៀបចំគោលដៅ និង របៀបយកគំរូតាង ដែលការសិក្សានេះត្រូវទទួលយកពីការសិក្សាលើកមុន។[២]

(តទៅទំព័រ ១៨)

# កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្នាក់ជាតិៈ ឧបករណ៍គន្លឹះដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយសមធម៌

*ដោយលោក* ***Julian Hansen****

## ប្រវត្តិ

នៅកម្ពុជារហូតមកដល់ពេលថ្មីៗនេះ ការផ្តល់សេវា និងការធ្វើផែនការអភិវឌ្ឍន៍សំដៅកាត់បន្ថយភាពក្រីក្រ នៅមិនទាន់បានផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ ទៅលើការកំណត់មុខសញ្ញាឱ្យបានច្បាស់លាស់ក្នុងការផ្តល់ជំនួយដល់ប្រជាពលរដ្ឋក្រីក្រ ។ កន្លងមកទោះជាមានការកំណត់មុខសញ្ញាបែបនេះក្តី ក៏ស្ថាប័ននីមួយៗបានរៀបចំ និងអនុវត្តនីតិវិធី និងលក្ខណៈវិនិច្ឆ័យរបស់ខ្លួនផ្ទាល់ ដើម្បីកំណត់ពីអ្នកត្រូវទទួលផលប្រយោជន៍ គឺបានន័យថា លទ្ធផលរកឃើញមិនអាចប្រៀបធៀបគ្នាបានទេ ហើយជាទូទៅក៏មិនដែលចែករំលែកទៅឱ្យអង្គការ ឬស្ថាប័នផ្សេងទៀតដែរ ។

នៅក្នុងវេទិកាថ្នាក់ជាតិមួយរៀបចំដោយក្រសួងផែនការ កាលពីខែកុម្ភៈ ២០០៥ មានការមូលមតិជាទូទៅស្តីពីតម្រូវការបង្កើតឱ្យមាននីតិវិធីស្តង់ដារថ្នាក់ជាតិមួយ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដើម្បីកាត់បន្ថយចំណាយរដ្ឋបាលទូទៅក្នុងការជ្រើសរើសក្រុមមុខសញ្ញា និងដើម្បីញ៉ាំងឱ្យការបែងចែកធនធានអភិវឌ្ឍន៍ដ៏កម្រ អាចធ្វើបានប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងបានទៅដល់ដៃអ្នកដែលត្រូវការវាជាងគេបំផុត ។ ក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រមួយ ដែលដឹកនាំដោយក្រសួងផែនការ និងមានជំនួយបច្ចេកទេសពីអង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) បានបង្កើតឡើងនៅខែមិថុនា ២០០៥ ជាអនុក្រុមមួយក្នុងក្រុមការងារបច្ចេកទេសស្តីពីផែនការ និងការកាត់បន្ថយភាពក្រីក្រ ។ សមាជិកក្រុមការងាររួមមានតំណាងមកពីក្រសួងជំនាញ ម្ចាស់ជំនួយ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ ក្រុមស្នូលតូចមួយបានធ្វើការនៅឆ្នាំ២០០៥ និង ២០០៦ ដើម្បីពិគ្រោះយោបល់ នឹងកសាងនីតិវិធីជាដំបូងៗ ព្រមទាំងបញ្ជីសំណួរស្តង់ដារមួយ សម្រាប់ធ្វើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតាមតំបន់ជនបទ (គេមិនទាន់ផ្តល់អាទិភាពឱ្យតំបន់ទីក្រុង នៅឡើយទេ) ។

ដើម្បីទទួលបាននូវជំនួយគាំទ្រក្នុងរយៈពេលមធ្យមសម្រាប់ការរៀបចំ និងការអនុវត្តឧបករណ៍ស្តង់ដារ ក្រសួងផែនការបានស្នើសុំជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស បន្ថែមពីរដ្ឋាភិបាលអាល្លឺម៉ង់ ។ រដ្ឋាភិបាលអាល្លឺម៉ង់បានផ្តល់ជំនួយនេះ នៅដើមឆ្នាំ២០០៦ ដោយជួលឱ្យ GTZ នៅកម្ពុជា ជួយដល់ក្រសួងផែនការតាមរយៈកម្មវិធី "ការគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" (IDPoor) ។ ការគាំទ្រនេះចាប់ផ្តើមនៅខែមេសា ២០០៦ ហើយដំណាក់កាលបច្ចុប្បន្ន នឹងចប់សព្វគ្រប់នៅដំណាច់ឆ្នាំ២០០៩ ។

## គោលដៅ

គោលដៅធំនៃកម្មវិធីរបស់ក្រសួងផែនការ គឺការប្រកាសទទួលស្គាល់ជាផ្លូវការនូវនីតិវិធីស្តង់ដារ ដើម្បីធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងបង្កើនការប្រើប្រាស់នីតិវិធីនេះឱ្យបានទូលំទូលាយ ក្នុងប្រទេសកម្ពុជា ។ ចំណុចសំខាន់មួយនៅក្នុងនេះ គឺត្រូវបញ្ចូលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាការងារប្រចាំរបស់ក្រុមប្រឹក្សាឃុំ និងអង្គភាពនានាដែលជួយទ្រទ្រង់ឃុំ (ឧ. អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង និងក្រុមសំរបសំរួលថ្នាក់ខេត្ត និងស្រុក) ។

គោលដៅសំខាន់មួយទៀតនៃកម្មវិធី គឺជំរុញការប្រើប្រាស់ជាទូទៅនូវទិន្នន័យប្រមូលបាន ដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល គំរោង/កម្មវិធីតាមវិស័យនានា និងក្រុមប្រឹក្សាឃុំ នៅក្នុងការងារកំណត់មុខសញ្ញា និងផ្តល់សេវានិងជំនួយដល់គ្រួសារក្រីក្រ ។

## អ្វីទៅជាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ? តើដើម្បីអ្វី?

យោងទៅលើនីតិវិធីដែលប្រើដោយក្រសួងផែនការនិងអង្គការដៃគូ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាការរកឱ្យឃើញគ្រួសារក្រីក្រ និងកំរិតភាពក្រីក្ររបស់គ្រួសារនីមួយៗដែលរស់នៅតំបន់ជនបទ ។ តាមវិធីនេះ ឈ្មោះនិង អាស័យដ្ឋាននៃគ្រួសារក្រីក្ររួមទាំងសមាជិកនីមួយៗត្រូវប្រមូល ។ គោលបំណងនៃការកំណត់អត្តសញ្ញាញគ្រួសារនីមួយៗនេះ គឺដើម្បីកំណត់គោលដៅសម្រាប់ផ្តល់សេវា និងជំនួយអភិវឌ្ឍន៍ ឱ្យចំគ្រួសារដែលក្រីក្រជាងគេនៅតាមភូមិ ដើម្បីជួយលើកស្ទួយពួកគេឱ្យចាកផុតពីភាពក្រីក្រ ព្រមទាំងការពារពួកគេឱ្យផុតពីគ្រោះថ្នាក់នានា (ដូចជា មានជម្ងឺធ្ងន់ធ្ងរ ការខូចខាតផលដំណាំ) ដែលធ្វើឱ្យពួកគេកាន់តែក្រីក្រខ្លាំងឡើង ។

ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក៏អាចប្រើផងដែរសម្រាប់គណនាកំរិតភាពក្រីក្រប្រៀបធៀប របស់ភូមិនានា ដោយផ្អែកលើចំនួនគ្រួសារក្នុងចំណាត់ថ្នាក់ភាពក្រីក្រទាំងពីរប្រភេទតាមភូមិនីមួយៗ ។ អ្នកផ្តល់សេវា អាចប្រើទិន្នន័យនេះ ដើម្បីកំណត់ឃុំ ឬភូមិដែលក្រីក្រជាងគេ និងគ្រួសារក្រីក្រនៅក្នុងតំបន់ទាំងនោះ ។

នៅកម្ពុជា ទិន្នន័យអំពីគ្រួសារក្រីក្រ អាចប្រើបានច្រើនយ៉ាង ដូចជាការផ្តល់សេវាព្យាបាលសុខភាព ដោយឥតគិតថ្លៃ រឺដោយចុះថ្លៃ (ឧ. តាមរយៈមូលនិធិសមធម៌សុខភាព រឺការធានារ៉ាប់រងសុខភាពសង្គម) អាហារូបករណ៍ ឬជំនួយហិរញ្ញវត្ថុ ដល់សិស្សក្រីក្រ សេវាអភិវឌ្ឍន៍ជនបទនិងវិស័យកសិកម្ម ការបែងចែកដីសម្បទានសង្គមកិច្ចដល់គ្រួសារក្រីក្រ និងការប្រើប្រាស់ផ្សេងៗទៀត ហើយទិន្នន័យនេះ ក៏មានសក្តានុពលសំរាប់ប្រើប្រាស់ក្នុងការកសាងកម្មវិធីផ្ទេរសាច់ប្រាក់ ដោយមានលក្ខខណ្ឌ រឺគ្មានលក្ខខណ្ឌផ្សេងៗ ។

## តើអត្តសញ្ញាណកម្មគ្រួសារក្រីក្រកំពុងអនុវត្តនៅកន្លែងណា?

នៅឆ្នាំ២០០៧ ក្រសួងផែនការ ដោយរួមសហការជាមួយក្រសួងមហាផ្ទៃ បានអនុវត្តសាកល្បងជាទ្រង់ទ្រាយតូច នូវគំរូដំបូងនៃនីតិវិធី និងបញ្ជីសំណួរបន្ទាប់មកបានធ្វើការកែសំរួល ហើយអនុវត្តនីតិវិធីជាទ្រង់ទ្រាយធំនៅខេត្តក្រចេះ (ខេត្តទាំងមូល) និង សៀមរាប (ស្រុកប្រតិបត្តិ (OD) សូទ្រនិគមនិងក្រឡាញ់) ។ នៅឆ្នាំ២០០៨ បានអនុវត្ត ពង្រីកទៅខេត្តឧត្តរមានជ័យទាំងមូល, ទៅ OD បី នៅខេត្តកំពង់ចាម គឺជើងព្រៃ/បាធាយ, ចំការលើ/ស្ទឹងត្រង់,

---

* Julian Hansen ជាប្រធានក្រុមនៃកម្មវិធី "ការគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" របស់អង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ ដែលមានទីតាំងនៅក្នុងក្រសួងផែនការ ។ ចំពោះព័ត៌មានបន្ថែមទាក់ទិននឹងកម្មវិធីនេះ សូមទាក់ទង:

**លោក ជា ចាន់ទុំ** អ្នកសំរបសំរួលគំរោងនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ ។ ទូរស័ព្ទ: ០១២ ៨៦៧ ៨៦៧/០២៣ ២២០ ៧៤០ អ៊ីមែល: idpoor@online.com.kh ឬ chantum@mop.gov.kh ។

ឬ លោក **Julian Hansen** ទូរស័ព្ទ: ០១២ ៤៧៦ ៩៩៥/០២៣ ២២០ ៧៤០ អ៊ីមែល: julian.hansen@gtz.org.kh ។

និងព្រៃឈរ/កងមាស និង OD ពីរ នៅខេត្តព្រៃវែង គឺពារាំង និង ព្រះស្តេច ។ ដូច្នេះមកដល់ខែកក្កដា ២០០៨ ក្រសួងផែនការបានកំណត់គ្រួសារក្រីក្រ ដោយប្រើនីតិវិធីថ្នាក់ជាតិ ក្នុង ៥ខេត្ត (ខេត្តទាំងមូល រឺមួយភាគ) រឺត្រូវជា ២១២៨ភូមិ ។

ក្នុងដើមឆ្នាំ២០០៩ ក្រសួងផែនការ អាចនឹងធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅស្រុកប្រតិបត្តិចំនួនពីរទៀត ក្នុងខេត្តកំពង់ចាម (មេមត់ និងពញាក្រែក) និង ខេត្តកំពង់ធំ និងកំពត ។ ក្រសួងកំពុងតែពិចារណាតំបន់ផ្សេងទៀត ដើម្បីអនុវត្តប្រសិនបើមានថវិកាគ្រប់គ្រាន់ ។

ព័ត៌មានត្រឡប់ ត្រូវបានប្រមូលតាមរយៈអ្នកអនុវត្តនិងអ្នកពាក់ព័ន្ធដំណើរការ ដើម្បីធ្វើការកែលំអនីតិវិធីនិង ការអនុវត្តរបស់ពួកគេ ។ម្យ៉ាងទៀត មានការពិគ្រោះយោបល់ជាប្រចាំជាមួយ ក្រុមការងារស្នូលថ្នាក់ជាតិ និងក្រុមការងារ ដើម្បីតំរង់ទិសយុទ្ធសាស្ត្រ និងកសាងគោលនយោបាយថែមទៀត ។

ជាបន្ថែមលើ ៥ខេត្ត ដែលក្រសួងផែនការបានអនុវត្តនីតិវិធីក្នុងខេត្តទាំងមូល ឬមួយភាគ ពួកអ្នកប្រើមូលនិធិសមធម៌ថែទាំសុខភាព និងដៃគូនានាក៏បានប្រើនីតិវិធីនេះក្នុងតំបន់មួយចំនួនទៀតដែរ ។ នៅឆ្នាំ២០០៧ និង ២០០៨ HSSC (គំរោងពង្រឹងប្រព័ន្ធសុខាភិបាលនៅកម្ពុជា) អនុវត្តដោយ University Research Company (URC) បានអនុវត្តនីតិវិធីថ្នាក់ជាតិនេះក្នុង ប្រាំ OD នៅខេត្តបន្ទាយមានជ័យ បាត់ដំបង និង ពោធិសាត់។ ក្នុងរយៈពេលនេះដែរ សមាគមអង្គការមិនមែនរដ្ឋាភិបាលខាងសុខភាពបន្តពូជនៅកម្ពុជា បានអនុវត្តនីតិវិធីនេះ ក្នុងប្រាំ ODs នៅ ក្រុងព្រះសីហនុ ខេត្តកំពង់ឆ្នាំង និង កំពង់ចាម ។ គំរោង HSSC ក៏មានគំរោងអនុវត្តនៅ ខេត្តរតនគីរី មណ្ឌលគីរី និងកោះកុង (ODs ស្រែអំបិល និងស្មាច់មានជ័យ) នៅចុងឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩ ។

តំបន់ទាំងអស់ដែលក្រសួងផែនការ និងអង្គការដៃគូបានអនុវត្តនីតិវិធីសុទ្ធតែជាកន្លែងដែលមានមូលនិធិសមធម៌សុខភាពកំពុងដំណើរការ ។ តំបន់ជាច្រើនក៏មានអ្នកផ្តល់សេវាប្រភេទផ្សេងទៀតច្រើនគួរសមដែរ ។ ក្រសួងផែនការយល់ថា គួរជ្រើសរើសជាសំខាន់នូវតំបន់នានាដែលមានសេវាច្រើនគ្រប់គ្រាន់ដើម្បីឱ្យសមនឹងការប្រឹងប្រែង និងបន្ទុកចំណាយលើការស្រាវជ្រាវ ព្រមទាំងមានលទ្ធភាពខ្ពស់ថា បណ្តាសហគមន៍ និងអាជ្ញាធរមូលដ្ឋាន នឹងទទួលស្គាល់ផលប្រយោជន៍នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។

## តើអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវអនុវត្តយ៉ាងដូចម្តេច?

ដំណើរការអត្តសញ្ញាណកម្មក្នុងភូមិនីមួយៗ ត្រូវធ្វើឡើងដោយក្រុមតំណាងភូមិ (ក.ត.ភ) ដោយមានការគាំទ្រ និងត្រួតពិនិត្យពីក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា ក្រុមប្រឹក្សាឃុំ និង អ្នកតំណាងមកពីក្រុមសំរបសំរួលស្រុក ។ ដំណើរការនេះសម្របសម្រួលដោយមន្ទីរផែនការខេត្ត ដោយរួមសហការជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ក្រសួងផែនការទទួលបន្ទុកផ្តល់ការបណ្តុះបណ្តាលថ្នាក់ខេត្ត ពិនិត្យតាមដានការអនុវត្ត និងផ្តល់ជំនួយគាំទ្របច្ចេកទេសជាប្រចាំ ។

ការងារអនុវត្តពឹងផ្អែកលើវិធីសាស្ត្រធ្វើការបណ្តុះបណ្តាលច្រើនដំណាក់។ បុគ្គលិកក្រសួងថ្នាក់ជាតិ បណ្តុះបណ្តាលសមាជិកនៃក្រុមសម្របសម្រួលថ្នាក់ខេត្ត និងក្រុមសម្របសម្រួលថ្នាក់ស្រុក ឱ្យក្លាយជាអ្នកបណ្តុះបណ្តាល ព្រមទាំងផ្តល់ជំនួយគាំទ្រដើម្បីឱ្យពួកគេអាចបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ ក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា ក្រុមតំណាងភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។

អត្តសញ្ញាណកម្មគ្រួសារក្រីក្រមាន ៧ជំហាន ដែលមានពិពណ៌នាលំអិតក្នុងឯកសារ *សៀវភៅណែនាំស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ* (ដែលមានចុះក្នុងវែបសាយ www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx) និង មានសេចក្តីសង្ខេបដូចតទៅ:

ជំហាន១: បង្កើត និងបណ្តុះបណ្តាល ក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា (ក្រុមតំណាង គ.ផ.ថ)
- រៀបចំប្រជុំគណៈកម្មាធិការកសាងផែនការនិងថវិកា ដើម្បីជ្រើសរើសក្រុមតំណាង គ.ផ.ថ
- បណ្តុះបណ្តាលសមាជិកក្រុមតំណាង គ.ផ.ថ
- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ឃុំ

ជំហាន២: ជ្រើសរើស និងបណ្តុះបណ្តាលក្រុមតំណាងភូមិនានា
- រៀបចំកិច្ចប្រជុំភូមិលើកដំបូង ដើម្បីជ្រើសរើសសមាជិកក្រុមតំណាងភូមិ
- គ្រូបង្គោលថ្នាក់ឃុំ បណ្តុះបណ្តាលក្រុមតំណាងភូមិ និងរៀបចំការសំភាសន៍សាកល្បង

ជំហាន៣: ក្រុមតំណាងភូមិ ចងក្រងបញ្ជីគ្រួសារក្នុងភូមិ សំភាសន៍គ្រួសារ និងចងក្រងបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ចងក្រងបញ្ជីឈ្មោះគ្រួសារក្នុងភូមិ
- ចងក្រងបញ្ជីគ្រួសារក្នុងភូមិសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- សំភាសន៍គ្រួសារ
- បូកសរុបពិន្ទុ និងរៀបចំបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ
- ពិភាក្សាក្នុងក្រុមតំណាងភូមិអំពីស្ថានភាពគ្រួសារ និងកែសម្រួលចំណាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារមួយចំនួនតាមការចាំបាច់
- រៀបចំកិច្ចប្រជុំថ្នាក់ឃុំ ដើម្បីត្រួតពិនិត្យបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ
- រៀបចំបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង

ជំហាន៤: រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិស្តីពីបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ការទទួលមតិជំទាស់របស់អ្នកភូមិ និងការរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ
- បិទផ្សាយជាសាធារណៈនៅក្នុងភូមិ នូវបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិ
- ទទួលមតិជំទាស់របស់អ្នកភូមិ
- រៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ និងបញ្ជូនទៅក្រុមប្រឹក្សាឃុំ

ជំហាន ៥: ការត្រួតពិនិត្យឡើងវិញ និងអនុម័តបញ្ជីគ្រួសារក្រីក្រចុងក្រោយដោយក្រុមប្រឹក្សាឃុំ និងការរៀបចំ ប័ណ្ណសមធម៌
- ក្រុមប្រឹក្សាឃុំត្រួតពិនិត្យឡើងវិញនូវ បញ្ជីគ្រួសារក្រីក្រចុងក្រោយរបស់ភូមិនីមួយៗនិងសម្របសម្រួលដោះស្រាយរាល់មតិជំទាស់ ឬសំណូមពររបស់អ្នកភូមិ
- ក្រុមប្រឹក្សាឃុំ អនុម័តទទួលស្គាល់បញ្ជីគ្រួសារក្រីក្រចុងក្រោយ ដែលរៀបចំដោយក្រុមតំណាងភូមិ
- ក្រុមប្រឹក្សាឃុំ បញ្ជូនទៅមន្ទីរផែនការខេត្ត នូវបញ្ជីគ្រួសារក្នុងភូមិ បញ្ជីគ្រួសារក្រីក្រចុងក្រោយ បញ្ជីសំណួរ និងសេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាឃុំស្តីពី ការអនុម័តទទួលស្គាល់បញ្ជីគ្រួសារក្រីក្រចុងក្រោយ
- ប្រធានក្រុមប្រឹក្សាឃុំចុះហត្ថលេខា និងបោះត្រាឃុំលើប័ណ្ណសមធម៌ រួចហើយប្រគល់ឱ្យក្រុមតំណាងភូមិ ដើម្បី ចែកឱ្យគ្រួសារក្រីក្រ (ក្រោយពីការបញ្ចូលទិន្នន័យ និងការថតរូបក្នុងជំហាន ៦ និង ៧)

ជំហាន ៦: មន្ទីរផែនការខេត្ត បញ្ចូលបញ្ជីគ្រួសារក្នុងភូមិ បញ្ជីគ្រួសារក្រីក្រចុងក្រោយ បញ្ជីសំណួរ រូបថតគ្រួសារក្រីក្រ នឹងតារាងតាមដានការថតរូបចូលក្នុងទិន្នន័យមូលដ្ឋាន គ្រួសារក្រីក្រ

ជំហាន ៧: ការថតរូបគ្រួសារក្រីក្រ
- ក្រុមថតរូបថតគ្រួសារក្រីក្រ

- មន្ទីរផែនការខេត្តបញ្ចូលទិន្នន័យទៅក្នុងទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ
- ការបោះពុម្ពប័ណ្ណសមធម៌ មន្ទីរផែនការខេត្តចែកចាយដល់ក្រុមប្រឹក្សាឃុំ

ដំណើរការខាងលើមានការពិគ្រោះយោបល់ និងចូលរួមពីអ្នកភូមិយ៉ាងច្រើន: អ្នកភូមិបោះឆ្នោតជ្រើសរើសក្រុមតំណាងភូមិ ហើយអ្នកភូមិមួយចំនួនបានក្លាយជាសមាជិកក្រុមតំណាងភូមិ ដើម្បីទទួលខុសត្រូវសំភាសន៍ ។ អ្នកភូមិចូលរួម ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិស្តីពីបញ្ជីគ្រួសារក្រីក្រលើកដំបូង ដើម្បីលើកនូវសំណូមពរឬមតិជំទាស់ដែលពាក់ព័ន្ធទៅនឹង បញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង និងបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ ។

សមិទ្ធផលនៃដំណើរការនៅថ្នាក់ឃុំនិងភូមិ គឺបញ្ជីគ្រួសារក្រីក្រចុងក្រោយក្នុងភូមិនីមួយៗ ។ ម្យ៉ាងទៀត អាស្រ័យលើតម្រូវការជាក់ស្តែង គ្រួសារដែលបានកំណត់ថាជាគ្រួសារក្រីក្រ គឺអាចទទួលបានប័ណ្ណសមធម៌ ។ ប័ណ្ណនេះបង្ហាញនូវព័ត៌មានមួយចំនួនដូចជា ឈ្មោះភូមិ ឃុំ ស្រុក និងខេត្ត, ឈ្មោះ ភេទ និងឆ្នាំកំណើតរបស់មេគ្រួសារ កំរិតភាពក្រីក្រ និងរូបថតគ្រួសារ ។ ប័ណ្ណនេះ ១) បញ្ជាក់ឱ្យគ្រួសារក្រីក្រដឹងថា ពួកគេអាចស្វែងរកសេវា ឬជំនួយផ្សេងៗដែលពួកគេមានសិទ្ធិនឹងទទួល ២) ជួយសម្រួលដល់អ្នកផ្តល់សេវាក្នុងការបញ្ជាក់ពីអត្តសញ្ញាណនៃសមាជិកគ្រួសារក្រីក្របានឆាប់រហ័សដើម្បីផ្តល់សេវាដល់ពួកគេ ។ បញ្ជីគ្រួសារក្រីក្រ ត្រូវបានធ្វើបច្ចុប្បន្នភាពពីរឆ្នាំម្តងដើម្បីរក្សានូវភាពសុក្រិត ។

## បញ្ជីសំណួរ

បច្ចុប្បន្នបញ្ជីសំណួរស្តង់ដារជាតិ ត្រូវបានប្រើប្រាស់នូវគ្រប់តំបន់ដែលអនុវត្តដោយក្រសួងផែនការ ឬអង្គការដៃគូ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលមួយដែលអាចប្រៀបធៀបគ្នាបានក្នុងចំណោមគ្រួសារ និងតំបន់ភូមិសាស្ត្រផ្សេងគ្នា (ភូមិ ឃុំ ស្រុក ខេត្ត) ។ បញ្ជីសំណួរមានសូចនាករសាមញ្ញធម្មតាៗមួយចំនួនដែលក្រុមការងារថ្នាក់ជាតិស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានឯកភាពគ្នាទទួលស្គាល់ថា អាចវាស់វែងភាពក្រីក្របានសមស្រប ។ សូចនាករទាំងនេះផ្អែកជាសំខាន់ទៅលើទ្រព្យសម្បត្តិ ដែលអាចសង្កេតមើលឃើញនិងងាយផ្ទៀងផ្ទាត់បាន ប៉ុន្តែក៏រួមបញ្ចូលផងដែរនូវបញ្ហាដទៃទៀតដូចជា អត្រាសមាជិកគ្រួសារដែលមិនអាចរកចំណូល ការខកខានរៀន វិបត្តិឬបញ្ហាចៃដន្យ និងស្ថានភាពពិសេសផ្សេងទៀតដែលធ្វើឱ្យពួកគេងាយរងគ្រោះ ។ ការសំភាសន៍ត្រូវបានធ្វើ ដោយក្រុមតំណាងភូមិដែលមាន ការយល់ដឹងច្បាស់លាស់ពីស្ថានភាពនៅមូលដ្ឋានដែលធ្វើឱ្យងាយស្រួលបញ្ជាក់ថា អ្នកផ្តល់ចម្លើយបានឆ្លើយត្រឹមត្រូវ ស្របតាមស្ថានភាពជាក់ស្តែងរបស់ពួកគេដែរឬទេ ។ ម្យ៉ាងទៀត សមាជិកក្រុមតំណាងភូមិអាចដឹងអំពីស្ថានភាពពិសេស របស់គ្រួសារដែលរស់នៅក្នុងភូមិរបស់គាត់ ។

បញ្ជីសំណួរមានសំនួរដាក់ពិន្ទុ និងសំណួរមិនដាក់ពិន្ទុ ។ សំណួរមានពិន្ទុទាំងនោះគឺជាមូលដ្ឋានចម្បងដើម្បីដាក់ចំណាត់ថ្នាក់ភាពក្រីក្រដល់គ្រួសារ ឬមិនបញ្ចូលពួកគេក្នុងបញ្ជីគ្រួសារក្រីក្រ ។ សំណួរនីមួយៗមានទម្ងន់ពិន្ទុខុសៗគ្នា អាស្រ័យទៅលើកម្រិតទំនាក់ទំនងជាមួយនឹងភាពក្រីក្រ ។ ទម្ងន់ទាំងនេះមិនត្រូវបានគណនាតាមបែបវិទ្យាសាស្ត្រទេ ប៉ុន្តែត្រូវបានសម្រេចដោយក្រុមការងារថ្នាក់ជាតិផ្អែកលើបទពិសោធន៍នៅមូលដ្ឋាន ។ ខ្លឹមសារនៃសំណួរទាំងនេះ ត្រូវបានសង្ខេបដូចខាងក្រោម:

- ស្ថានភាពផ្ទះ: ដំបូល ជញ្ជាំង ផ្ទៃក្រឡា និងស្ថានភាពទូទៅនៃផ្ទះ
- ទំហំផ្ទៃដីធ្វើស្រែចំការ គិតជាហិកតា ឬ ឧបករណ៍នេសាទ ឬប្រភពចំណូលផ្សេងទៀតដូចជា ប្រាក់ឈ្នួល ប្រាក់បៀវត្ស ឬការធ្វើអាជីវកម្ម
- ការចិញ្ចឹមសត្វ (រួមទាំងការចិញ្ចឹមត្រីដើម្បីលក់)
- ការខ្វះបុលស្រូវ (បញ្ជាក់ពីភាពមានលទ្ធភាព ឬ គ្មានលទ្ធភាពបំពេញតម្រូវការស្បៀងអាហារ)
- សមាមាត្រសមាជិកដែលមិនអាចរកប្រាក់ចំណូលបាន
- ទ្រព្យសម្បត្តិ (ជាពិសេសឧបករណ៍អេឡិចត្រូនិក)
- មធ្យោបាយធ្វើដំណើរ (រួមទាំងទូក សំរាប់ភូមិបណ្តែតទឹក)

ក្នុងបញ្ជីសំណួរ ក៏មានសំណួរមួយចំនួនមិនដាក់ពិន្ទុដែរ (ពាក់ព័ន្ធបញ្ហាមួយចំនួនដែលពិបាកកំណត់ពិន្ទុ) សម្រាប់សមាជិកក្រុមតំណាងភូមិពិភាក្សានិងពិចារណាលើផលប៉ះពាល់ដល់គ្រួសារក្រីក្រទាំងនោះ ។ ក្រុមតំណាងភូមិក៏ត្រូវយកចិត្តទុកដាក់ផងដែរលើព័ត៌មាន សំណូមពរ មតិជំទាស់ ដែលលើកឡើងដោយអ្នកភូមិក្នុងអំឡុងដំណើរការពិគ្រោះយោបល់ជាសាធារណៈ។ ព័ត៌មាននេះ អាចត្រូវបានប្រើប្រាស់ដោយក្រុមតំណាងភូមិដើម្បីកែសម្រួលចំណាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារ ។ បញ្ជីសំណួរមិនដាក់ពិន្ទុ គ្របដណ្តប់បញ្ហាដូចខាងក្រោម:

- បញ្ហាឬវិបត្តិចៃដន្យដែលបណ្តាលអោយគ្រួសារបាត់បង់ប្រាក់ចំណូល ខ្វះស្បៀងអាហារ លក់ទ្រព្យសម្បត្តិ ឬខ្ចីលុយគេក្នុងរយៈពេល១២ខែកន្លងមក
- ចំនួនក្មេងអាយុ៦-១១ឆ្នាំ ដែលមិនបានចូលរៀននិងខកខានរៀនអស់រយៈពេលយ៉ាងតិច១ខែនៅក្នុងអំឡុង ពេល១២ខែ កន្លងមក
- ស្ថានភាពពិសេសរបស់គ្រួសារ (ពិការភាព ជំងឺ ចាស់ជរា ស្ត្រីមេម៉ាយដែលមានកូនតូចៗច្រើន គ្មានមនុស្សពេញវ័យ ឬស្ថានភាពដទៃទៀត)

ចំពោះព័ត៌មានលំអិតអំពីបញ្ជីសំណួរ សូមមើលវែបសាយ www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx ។

## ចំណាត់ថ្នាក់ភាពក្រីក្រ

មានចំណាត់ថ្នាក់ភាពក្រីក្រពីរ សម្រាប់ដាក់ឱ្យគ្រួសារក្រីក្រ: ក្រកំរិតទី១ (ក្រីក្របំផុត) ឬក្រកំរិតទី២ (ក្រីក្រ) ។ ចំណាត់ថ្នាក់ភាពក្រីក្រទាំងនេះត្រូវបានកំណត់ដោយផ្អែកលើពិន្ទុក្នុងបញ្ជីសំណួរ (ដោយយោងតាមចន្លោះ ពិន្ទុដែលបានកំណត់) និងការពិចារណាលើស្ថានភាពពិសេសរបស់គ្រួសារនោះ ។ សមាមាត្រគ្រួសារដែលស្ថិតក្នុងចំណាត់ថ្នាក់ភាពក្រីក្រទាំងពីរ ត្រូវបានក្រិតអោយស្របទៅនឹងលទ្ធផលនៃ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ (ដែលមានការប្រែប្រួលខ្លះៗហើយ) ។ ក្រកំរិតទី១ មានសមាមាត្រប្រហាក់ប្រហែលនឹង សមាមាត្រគ្រួសារដែលស្ថិតក្រោមខ្សែបន្ទាត់ភាពក្រីក្រផ្អែកម្ហូបអាហារដែលកំណត់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា រីឯក្រកំរិតទី២ ក៏មានសមាមាត្រប្រហាក់ប្រហែលនឹង គ្រួសារដែលស្ថិតក្នុងចន្លោះរវាងខ្សែបន្ទាត់ភាពក្រីក្រផ្អែកម្ហូបអាហារ និងខ្សែបន្ទាត់ភាពក្រីក្រដែលកំណត់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច កម្ពុជា ។ ជាមធ្យម មានប្រហែលមួយភាគបីនៃគ្រួសារសរុបត្រូវបានដាក់ក្នុងចំណាត់ថ្នាក់ក្រកំរិតទី១ ឬ ក្រកំរិតទី២ រួចបញ្ចូលទៅក្នុងបញ្ជីគ្រួសារក្រីក្រ ។

## ចំណុចខ្លាំង និងកំហិតនៃវិធីសាស្ត្រ

កម្មវិធីផ្តោតជាសំខាន់ទៅលើ ការប្រើប្រាស់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តដោយរចនាសម្ព័ន្ធរដ្ឋាភិបាលនិងតំណាងភូមិ ដើម្បីកសាងសមត្ថភាពនៅមូលដ្ឋាននិងជំរុញការអនុវត្តអោយមាននិរន្តរភាព ។ ប៉ុន្តែ ការសង្កត់ធ្ងន់លើការកសាងសមត្ថភាពនេះតម្រូវឱ្យមានការបណ្តុះបណ្តាលច្រើនគួរឱ្យកត់សម្គាល់ដែលបង្កើនការចំណាយ ។

នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានការចូលរួមយ៉ាងខ្លាំងក្លាដោយអ្នកភូមិ ក៏ដូចជាការពិគ្រោះយោបល់រវាងអ្នកភូមិផ្ទាល់ ។ ការចូលរួមនេះ

បង្កើនតម្លាភាពនិងភាពត្រឹមត្រូវនៃលទ្ធផល ដែលធ្វើឱ្យអ្នកមូលដ្ឋាន និងអ្នកប្រើប្រាស់ទិន្នន័យងាយទទួលស្គាល់លទ្ធផល ។ ក៏ប៉ុន្តែ ការធ្វើដូច្នេះ បង្កើននូវភាពស្មុគស្មាញ និងពេលវេលាដែលត្រូវចំណាយខ្លះ ។

ផលវិជ្ជមានប្រយោលនៃដំណើរការនេះ គឺជាការពង្រឹងនូវលិទ្ធិប្រជាធិបតេយ្យក្នុងសហគមន៍ ដូចជា បង្កើននូវ ការគិតគូររបស់អ្នកដឹកនាំមូលដ្ឋានអំពីសុខមាលភាពប្រជាពលរដ្ឋ និងកំរិតនៃគណនេយ្យភាពចំពោះប្រជាពលរដ្ឋ, ការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងសកម្មក្នុងកិច្ចការសហគមន៍ និងបង្កើនការពិគ្រោះយោបល់និងតម្លាភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។

ទោះបីជាការប្រើប្រាស់បញ្ជីសំណួរស្តង់ដារ មានសារៈសំខាន់ដើម្បីប្រៀបធៀបលទ្ធផលពីតំបន់មួយទៅតំបន់ផ្សេងទៀត ក៏អាចមានសំណួរខ្លះមិនអាចយកទៅប្រើប្រាស់នៅគ្រប់តំបន់ ឬជាមួយគ្រប់ជនជាតិ និងប្រភេទជីវភាព ។បញ្ហានេះអាចតម្រូវឱ្យធ្វើការកែសម្រួលបញ្ជីសំនួរតាមបទពិសោធន៍ដែលទទួលបានពីការអនុវត្ត ។

ចំពោះការប្រើប្រាស់បញ្ជីសំណួរ សមាជិកក្រុមតំណាងភូមិជួបប្រទះបញ្ហាស្មុគស្មាញខ្លះ ប៉ុន្តែដោយមានការបណ្តុះបណ្តាលនិងការណែនាំសមាជិកក្រុមតំណាងភូមិ ពួកគេមានសមត្ថភាពប្រើប្រាស់បញ្ជីសំណួរនេះ ។ ដោយសារតែមានសម្ពាធខ្លាំងពី សហគមន៍ដើម្បីបញ្ចូលគ្រួសារក្នុងបញ្ជីគ្រួសារក្រីក្រ ដូច្នេះបញ្ជីសំណួរគឺជាឧបករណ៍ដ៏សំខាន់ដើម្បី បង្កើនភាពយុត្តិធម៌ក្នុង ការកំណត់កំរិតភាពក្រីក្រគ្រួសារ ។

## ទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ

ទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ ត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងផលិតទិន្នន័យសម្រាប់អ្នកផ្តល់សេវា ។ ទិន្នន័យមូលដ្ឋាននេះត្រូវបានរៀបចំនៅកម្ពុជាហើយអាចប្រើបានជាពីរភាសា (ភាសាខ្មែរ និងអង់គ្លេស) ។ ទិន្នន័យមូលដ្ឋានត្រូវបានរៀបចំជាទម្រង់មួយដែលអនុញ្ញាតឱ្យមានការបញ្ចូលទិន្នន័យនៅតំបន់ផ្សេងៗគ្នាបាន បន្ទាប់មកអាចផ្តុំទិន្នន័យទាំងនោះនៅថ្នាក់ជាតិ ។ នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយក្រសួងផែនការ មានមន្ទីរផែនការខេត្តទទួលខុសត្រូវបញ្ចូលទិន្នន័យ ។ ក្រសួងផែនការ ក៏ផ្តល់ទិន្នន័យមូលដ្ឋានដល់អង្គការដៃគូដើម្បីបញ្ចូលទិន្នន័យក្នុងតំបន់ដែលពួកគេគ្របដណ្តប់ ។ គោលបំណងរបស់ក្រសួងផែនការ គឺដើម្បីផ្តុំទិន្នន័យដែលបានមកពីតំបន់ដែលគ្របដណ្តប់ដោយក្រសួងផែនការក៏ដូចជា អង្គការដៃគូ ហើយទិន្នន័យទាំងនោះអាចចែករំលែកដល់អ្នកផ្តល់សេវាដើម្បី ធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលទិន្នន័យធៀបនឹងការចំណាយ ។

## ប្រភេទទិន្នន័យដែលមាន

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រអាចផ្តល់នូវទិន្នន័យច្រើនប្រភេទសម្រាប់ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល កម្មវិធីនិងគម្រោងតាមវិស័យដើម្បីប្រើប្រាស់សំរាប់ផ្តល់សេវា និងជំនួយដល់គ្រួសារក្រីក្រប្រកបដោយប្រសិទ្ធភាព ។ ទិន្នន័យទាំងនេះមានដូចជាៈ

- បញ្ជីគ្រួសារក្រីក្រច្បាប់ដើមសរសេរដោយដៃលើក្រដាស់ មានច្បាប់ចម្លងរក្សាទុកនៅភូមិ និងឃុំភ្លាមៗ បន្ទាប់ពីក្រុមប្រឹក្សាឃុំបានអនុម័តបញ្ជីគ្រួសារក្រីក្រ (មុនដំណើរការបញ្ចូលទិន្នន័យ) ។
- របាយការណ៍ចេញពីទិន្នន័យមូលដ្ឋានមានដូចជាៈ
  - បញ្ជីគ្រួសារក្រីក្រដែលមាននូវឈ្មោះ និងភេទមេគ្រួសារ ឈ្មោះប្តីឬប្រពន្ធមេគ្រួសារ និងកំរិតភាពក្រីក្រ
  - ការពិពណ៌នាសង្ខេបអំពីសមាជិកគ្រួសារទាំងអស់ដែលមាន ឈ្មោះ ភេទ អាយុ ឆ្នាំកំណើត ទំនាក់ទំនងជាមួយមេគ្រួសារ នៃសមាជិកនីមួយៗ និងកំរិតភាពក្រីក្រ
  - របាយការណ៍ប្រៀបធៀបអត្រាក្រីក្រៈ បង្ហាញនូវភាគរយសរុបនៃក្រកំរិតទី១ ក្រកំរិតទី២ និង គ្រួសារក្រីក្រក្នុងភូមិទាំងអស់ សំរាប់គ្រប់ភូមិក្នុងតំបន់គ្របដណ្តប់ ។ របាយការណ៍នេះ ក៏អាចវិភាគអត្រាភាពក្រីក្រធៀបទៅនឹងចំនួនប្រជាជន ។
  - ស្ថិតិសង្ខេបសម្រាប់តំបន់គ្របដណ្តប់ៈ បង្ហាញនូវភាគរយមេដ្យាន នៃគ្រួសារក្រកំរិតទី១និងក្រកំរិតទី២ ភាគរយមេដ្យានសរុបនៃគ្រួសារក្រីក្រក្នុងភូមិ ភាគរយមេដ្យាននៃមនុស្សនៅក្នុង គ្រួសារក្រីក្រកំរិតទី១ និងក្រកំរិតទី២ ភាគរយមេដ្យាននៃអ្នកក្រីក្រសរុបក្នុងភូមិ និងភាគរយនៃគ្រួសារដែលមានមេគ្រួសារជាស្ត្រី និងជាបុរសដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ភាពក្រីក្រនីមួយៗ ។
  - បញ្ជីឈ្មោះនិងរូបថតសមាជិកគ្រួសារក្រីក្រៈ មានរូបថតគ្រួសារខ្នាតតូច កំរិតភាពក្រីក្រ ឈ្មោះ ភេទ និងឆ្នាំកំណើតនៃសមាជិកគ្រួសារទាំងអស់ ។ បញ្ជីនេះអាចបោះពុម្ភចេញជាទម្រង់ សៀវភៅដែលងាយស្រួលប្រើដោយអ្នកផ្តល់សេវានៅថ្នាក់មូលដ្ឋានដែលមិនមានលទ្ធភាពប្រើកុំព្យូទ័រ ។
- កម្មវិធីទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រពេញ មានរូបថតគ្រួសារក្រីក្រនិងព័ត៌មានលម្អិតអំពីគ្រប់សមាជិកទាំងអស់ ហើយអាចបង្កើតរបាយការណ៍តាមការជ្រើសរើសប្រភេទទិន្នន័យដោយអ្នកប្រើប្រាស់ ។

## តំបន់ដែលមានទិន្នន័យ

បច្ចុប្បន្ន ក្រសួងផែនការមានទិន្នន័យពីជុំទី១នៃការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលបានអនុវត្តក្នុងឆមាសទីពីរ ឆ្នាំ២០០៧ នៅខេត្តក្រចេះទាំងមូល (ស្រុកប្រតិបត្តិឆ្លូង និងក្រចេះ) និងខេត្តសៀមរាប (ស្រុកប្រតិបត្តិ សូទ្រនិគម និងក្រឡាញ់) ។

ទិន្នន័យជុំទីពីរ ដែលបានមកពីការអនុវត្តក្នុងឆមាសទីមួយឆ្នាំ២០០៨ នឹងមានសំរាប់ចែកចាយនៅខែកញ្ញា ឬតុលា ឆ្នាំ២០០៨ ។ ទិន្នន័យនេះគ្របដណ្តប់ខេត្តសៀមរាប (ស្រុកប្រតិបត្តិអង្គរជុំ និងសៀមរាប) ខេត្តឧត្តរមានជ័យទាំងមូល ខេត្តកំពង់ចាម (ស្រុកប្រតិបត្តិជើងព្រៃ-បាធាយ, ចំការលើ-ស្ទឹងត្រង់, និងព្រៃឈរ-កងមាស) ខេត្តព្រៃវែង (ស្រុកប្រតិបត្តិពារាំង និងព្រះស្តេច) ។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ នឹងខិតខំផ្តុំទិន្នន័យដែលប្រមូលដោយអង្គការដៃគូក្នុង ឆ្នាំ២០០៨ នៅក្នុងខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ និងកំពង់ចាម (ស្រុកប្រតិបត្តិដែលបានគ្របដណ្តប់) បន្ទាប់មកនឹងធ្វើការផ្សព្វផ្សាយទិន្នន័យទាំងនេះ ។ ក្នុងឆ្នាំ ២០០៩ នឹងមានទិន្នន័យគ្រួសារក្រីក្រនៃ ខេត្តរតនៈគីរី និងមណ្ឌលគីរី និងស្រុកប្រតិបត្តិស្រែអំបិល និងស្មាច់មានជ័យខេត្តកោះកុង ។

## ទស្សនៈវិស័យ

បច្ចុប្បន្ន ធនធានរបស់ក្រសួងផែនការនៅមានកំរិត ដូច្នេះអាចប្រើប្រាស់សម្រាប់រៀបចំ អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងតំបន់គោលដៅមួយចំនួនក្នុងប្រទេសតែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះក្រសួងផែនការ កំពុងសហប្រតិបត្តិការជាមួយអង្គការដៃគូដើម្បីគ្របដណ្តប់តំបន់ផ្សេងទៀត ជាពិសេសផ្តោត

(តទៅទំព័រ ១៨)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសេដ្ឋកិច្ចនៃប្រទេសចំបងៗមួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីខាងកើត នៅត្រីមាសទី១ ឆ្នាំ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០០៨ ផសស ពិតនៅសហរដ្ឋអាមេរិក កើន ២,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ កំនើននេះឆ្លុះបញ្ចាំងនូវការរួមចំនែកជាវិជ្ជមានពីចំនាយប្រើប្រាស់ផ្ទាល់ខ្លួន និងចំនាយលើសេវាកម្ម ការនាំចេញទំនិញ និងសេវា ព្រមទាំង ចំនាយរដ្ឋាភិបាលសហព័ន្ធ ដែលកាត់កងវិញអស់មួយភាគដោយការរួមចំនែកអវិជ្ជមាន ពីវិនិយោគជាប់លាប់លើការស្នាក់នៅ ចំនាយប្រើប្រាស់ផ្ទាល់ខ្លួន ហើយនិង ចំនាយលើទំនិញប្រើបានយូរ ។ កំនើន ផសស ពិតនៅតំបន់អឺរ៉ូ ថយមកត្រឹម ២,២% ក្នុងរយៈមួយឆ្នាំ ធៀបនឹង ៣,០% ក្នុង រយៈមួយឆ្នាំដល់ត្រីមាសទី១ ឆ្នាំ២០០៧។ កំនើន ប្រចាំឆ្នាំនៅជប៉ុន គឺ ១,៣% ធៀបនឹង ២,០% នៅត្រីមាសទី៤ ឆ្នាំ២០០៧ និង ២,២% នៅត្រីមាសទី១ ឆ្នាំ២០០៧។

ផសស ពិតនៅចិន កើន ១០,៦% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំមុន ប៉ុន្តែវាថយចុះបន្តិច ធៀបនឹងអត្រា ១១,២% នៅត្រីមាសមុន ។ ការថយចុះកំនើនបន្តិចនេះ បណ្តាលពីការធ្លាក់ចុះការនាំចេញសុទ្ធរបស់ចិន។ កំនើន ផសស ពិតនៅកូរ៉េខាងត្បូង គឺ ៥,៧% ដែលដូចគ្នានឹងកំនើននៅត្រីមាសទី៤ ដែរ ប៉ុន្តែវាខ្ពស់ជាងកំនើននៅត្រីមាសទី១ឆ្នាំ២០០៧ ។ កំនើននេះបានជាចំបងពីកំនើនរឹងមាំយូរអង្វែងក្នុងវិស័យផលិតកម្ម និងកំនើនយ៉ាងខ្លាំងខាងទំនិញនាំចេញ ។ អត្រាកំនើន ផសស ពិតនៅតៃវ៉ាន់ និង កូរ៉េខាងត្បូង គឺ ៦,១% និង ៦,៨% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧។ ធៀបនឹងត្រីមាសមុន អត្រាកំនើននេះប្រែប្រួលតិចតួច ។

នៅម៉ាឡេស៊ី កំនើនពីមួយឆ្នាំទៅមួយឆ្នាំ គឺ ៧,១% ដែលប្រែប្រួលតិចតួចធៀបនឹងត្រីមាសមុន។ កំនើននេះបានពី កំនើនលេខពីរខ្ទង់នៃចំនាយប្រើប្រាស់ចុងក្រោយ (១១,៨%) ព្រមទាំង កំនើនយ៉ាងខ្លាំងក្នុងផលិតកម្ម (៦,៩%) និង សេវាកម្ម (៨,០%) ។ កំនើន ផសស ពិតនៅសិង្ហបុរី ក្នុងរយៈ១២ខែ គឺ ៧,២% ដែល ខ្ពស់ជាងកំនើន នៅត្រីមាសទី១ និង ទី៤ ឆ្នាំ២០០៧។ កំនើននេះបានពីការស្ទុះឡើងយ៉ាងខ្លាំងខាងផលិតកម្ម (១២,២%) សំនង់ (១៤,៧%) និងសេវាកម្មហិរញ្ញវត្ថុ (១៣,៤%)។ រីឯកំនើន ផសស ពិតនៅថៃ ទោះបីវាខ្ពស់ជាងត្រីមាសទី១ ឆ្នាំ២០០៧ ក្តី ប៉ុន្តែធៀបនឹងត្រីមាសមុនវាគ្មានកំនើនអ្វីជាដុំកំភួនទេ ។ កំនើនបានជាចំបងពីការរើបឡើងវិញខាងវិនិយោគ និងចំណាយប្រើប្រាស់ដែលបានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០៧ ។ កំនើននៃវិនិយោគជាប់លាប់ មាន ៥,៤% ចំណាយប្រើប្រាស់ឯកជនមាន ២,៦% និងការនាំចេញទំនិញនិងសេវា ៨,៧% ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០០៨ ថ្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិក កើន ៤,១% (២,៤% នៅត្រីមាសដូចគ្នាឆ្នាំមុន) ដែលបណ្តាលមកពី កំនើនថ្លៃម្ហូបអាហារនិងភេសជ្ជៈ ផ្ទះ ការថែទាំសុខភាព ការអប់រំ និង ទូរគមនាគមន៍ ។ អតិផរណាក្នុងរយៈ១២ខែនៅតំបន់អឺរ៉ូ គឺ ៤,១% ដែលខ្ពស់ជាងនៅត្រីមាសទី១ និង ទី៤ ឆ្នាំ២០០៧ ។ កត្តាជំរុញកំនើននេះ គឺការឡើងថ្លៃយ៉ាងខ្ពស់នៃថាមពល ម្ហូបអាហារកែច្នៃ និងសេវាកម្ម។ នៅត្រីមាសទី១ ឆ្នាំ២០០៧ អតិផរណានៅជប៉ុនកើនដល់ ១,០% ដែលខ្ពស់ជាងនៅត្រីមាសទី១ និង ទី៤ ឆ្នាំ២០០៧ និងដែលផុសចេញពីការស្ទុះឡើងយ៉ាងខ្លាំងនៃថ្លៃថាមពល និងម្ហូបអាហារ ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ក្នុងទីផ្សារប្តូរប្រាក់បរទេស ដុល្លារUS ឡើងថ្លៃទល់នឹង ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដោយប្តូរបាន ៨,១យ៉ុន/ដុល្លារUS និង ៩៥៥,៩វ៉ុន/ដុល្លារUS ប៉ុន្តែវាធ្លាក់ថ្លៃទល់នឹងប្រាក់យ៉េនជប៉ុន និង ប្រាក់បាតថៃ ដោយប្តូរបាន ១០៥,៣យ៉េន/ដុល្លារUS និង ៣០,៩បាត/ដុល្លារUS ។ អត្រាប្តូរប្រាក់អឺរ៉ូ-ដុល្លារ នៅថេរដដែលក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០០៨ នេះ ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០០៨ ថាមពល និងផលិតផលកសិកម្មជាច្រើន ដូចជា ពោត ប្រេងឆា អង្ករ និងសណ្តែកសៀង ជាដើម បន្តឡើងថ្លៃនៅទីផ្សារអន្តរជាតិ ។ ពោតឡើងថ្លៃ ២៦% ដល់ ១៩៨,៤ដុល្លារUS/តោន ហើយ សណ្តែកសៀងឡើងថ្លៃ ២២% ដល់ ៤៤៩,៦ដុល្លារUS/តោន ។ ប្រេងឆាឡើងថ្លៃដល់១០៤៨,៥ ដុល្លារUS /តោន ហើយ អង្ករថៃ 100% B ឡើងដល់ ៤៤៤,៤ដុល្លារUS/តោន ។ម្យ៉ាងទៀត ប្រេងនៅឡើងថ្លៃ ១៣%, សាំង ១៨%, និង ម៉ាស៊ូត ១១%។ ប្រេងនៅលក់ថ្លៃ ៩៣,៨ដុល្លារUS/ធុង រីឯសាំង និងម៉ាស៊ូត លក់ថ្លៃ ៦៤,២សេន/លីត្រ និង ៧៤,០សេន/លីត្រ ៕

*រៀបរៀងដោយ លោក សាំង ច័ន្ទហង្ស*

---

## ឯកសារចេញផ្សាយប្រចាំខែរបស់វិទ្យាស្ថាន CDRI

ឯកសារនេះ បង្ហាញជូនជាទៀងរាល់ខែនូវសូចនាករសេដ្ឋកិច្ចសំខាន់ៗ ទាំងសំរាប់ប្រទេសកម្ពុជា និងបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ។ សូចនាករ មានជាអាទិ៍ ការនាំចេញ ចំនួនទេសចរចូលមកប្រទេសកម្ពុជា ប្រតិបត្តិការថវិកាជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កំណើនផលិតផលក្នុងស្រុកសរុប ប្រាក់សន្សំក្នុងស្រុក អត្រាប្តូរប្រាក់រៀលជាមួយប្រាក់ដុល្លារ និង រូបិយវត្ថុប្រទេសជិតខាង ។


ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
Cambodia Development Resource Institute

របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា
Flash Report on the Cambodian Economy

សីហា ២០០៨ / August 2008

សាំង ច័ន្ទហង្ស / Saing Chan Hang
ផាន់ ដាលីស / Phann Dalis
ប៉ុន ដូរីណា / Pon Dorina
ហ៊ីង វុទ្ធា / Hing Vutha
ភឹម រុនស៊ីណារិទ្ធិ / Phim Runsinarith

បកប្រែដោយ: យូ សិទ្ធិរិទ្ធ និង ទុច ជរិទ្ធរៀ

ភ្នំពេញ កម្ពុជា
Phnom Penh, Cambodia

TO SUBSCRIBE, PLEASE CONTACT:
Office Address: #56, Street 315, Tuol Kork, Phnom Penh, Cambodia, Postal Address: CDRI, PO Box 622 Phnom Penh, Cambodia
Tel: (855-23) 881-384/881-701/881-916/883-603 Fax: (855-23) 880-734 E-mail: pubs@cdri.forum.org.kh. Web site: http://www.cdri.org.kh

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | - | 10.1 | 8.1 | 13.6 | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | - | 6.4 | 6.5 | 6.3 | 6.3 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 5.3 | 5.7 | 6.7 | 7.3 | 7.1 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 6.0 | 8.2 | 8.9 | 6.0 | 7.2 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 4.3 | 4.4 | 4.8 | 5.7 | 6.0 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.1 | 11.5 | 11.4 | 11.2 | 10.6 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 5.6 | 6.9 | 6.2 | 6.7 | 6.8 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 4.0 | 4.5 | 5.2 | 5.7 | 5.7 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 4.1 | 5.07 | 6.9 | 6.4 | 6.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 3.0 | 2.5 | 2.7 | 2.2 | 2.2 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 2.2 | 2.3 | 1.9 | 2.0 | 1.3 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 1.5 | 3.8 | 4.9 | 2.5 | 2.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 3.0 | 4.6 | 6.0 | 9.6 | - |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.4 | 6.0 | 6.5 | 6.7 | 7.6 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 2.6 | 1.4 | 1.8 | 2.2 | 2.6 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 0.5 | 1.0 | 2.7 | 4.1 | 6.6 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 2.4 | 1.9 | 1.7 | 2.9 | 5.0 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 6.6 | 7.4 | 8.6 | 10.7 | 16.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 2.6 | 3.6 | 6.1 | 6.6 | 8.0 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 1.7 | 1.3 | 1.6 | 3.5 | 4.6 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.0 | 2.4 | 2.3 | 3.3 | 3.7 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 1.0 | 0.3 | 1.4 | 4.5 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.9 | 1.9 | 1.9 | 2.9 | 3.4 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | -0.1 | -0.1 | -0.1 | 0.5 | 1.0 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 2.4 | 2.7 | 2.4 | 3.9 | 4.1 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4046.7 | 4065.7 | 4078 | 4026 | 3995.3 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 9107 | 8968.3 | 9257.8 | 9240.2 | 9217 |
| ម៉ាឡេស៊ី ( រីងហ្គីត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.50 | 3.43 | 3.46 | 3.35 | 3.18 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.53 | 1.52 | 1.52 | 1.45 | 1.41 |
| ថៃ ( បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 33.9 | 32.5 | 31.4 | 33.87 | 30.95 |
| វៀតណាម ( ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,356 | 16,125 | 16,105 | 16,030 | 16,125 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ន) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.76 | 7.68 | 7.55 | 7.43 | 8.01 |
| ហុងកុង ( ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.81 | 7.82 | 7.81 | 7.77 | 7.79 |
| កូរ៉េខាងត្បូង ( វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 939 | 929 | 927 | 921.23 | 955.89 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 32.9 | 33.1 | 32.9 | 32.4 | 31.52 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ ( អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.76 | 0.74 | 0.73 | 0.69 | 0.7 |
| ជប៉ុន ( យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 119.4 | 120.8 | 117.7 | 113.07 | 105.3 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 154.33 | 146.10 | 139.81 | 156.9 | 198.39 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 552.06 | 691.44 | 745.86 | 841.39 | 1048.49 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 294.17 | 283.89 | 304.75 | 323.92 | 444.43 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 255.33 | 259.95 | 299.99 | 366.59 | 449.64 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 54.21 | 65.41 | 72.48 | 82.88 | 93.77 |
| សាំង - US Gulf Coast ( សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 41.71 | 57.93 | 55.49 | 59.48 | 64.21 |
| ម៉ាស៊ូត ( ស្ពាន់ធ័រតិច លេខ២) - US Gulf Coast ( សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 45.61 | 53.90 | 56.62 | 66.54 | 73.99 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅត្រីមាសទី១ ឆ្នាំ២០០៨ ដំណើរការសេដ្ឋកិច្ចកម្ពុជាបានកើនឡើងយឺតៗ ។ ធៀបនឹងត្រីមាសមុន អនុមតិគំរោងវិនិយោគ នឹងសាងសង់ បានធ្លាក់ចុះយ៉ាងខ្លាំង រីឯពាណិជ្ជកម្មជាទូទៅបានកើនឡើង ។ ចំនួនភ្ញៀវមកដល់ កើនឡើងបន្តិច រីឯទំនិញប្រើប្រាស់នៅតែបន្តឡើងថ្លៃ ។

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ អនុមតិគំរោងវិនិយោគសរុបថយចុះ ៦៦% ធៀបនឹងឆ្នាំមុន មកត្រឹម ២៥៣,៤លានដុល្លារ ។ វិនិយោគលើវិស័យទាំងបី បានធ្លាក់ចុះយ៉ាងខ្លាំង ក្នុងនោះ វិនិយោគខាងកសិកម្មថយចុះ ៤៩% មកត្រឹម ៥២,៣លានដុល្លារ ខាងសេវាកម្មថយចុះ ៥២% មកត្រឹម ១៤៨,២លានដុល្លារ ហើយខាងឧស្សាហកម្មថយចុះយ៉ាងខ្លាំងអស់ ៨៤% មកត្រឹម ៥២,៩លានដុល្លារ ។ ជាទូទៅ ត្រីមាសទី១ គឺជាអំឡុងពេលដែលអនុមតិគំរោងវិនិយោគ កើនឡើង ។ ការធ្លាក់ចុះកំនើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក បានជះឥទ្ធិពលជាខ្លាំងដល់ការធ្លាក់ចុះវិនិយោគនៅកម្ពុជា ។ បរិយាកាសនយោបាយមិនសូវច្បាស់លាស់ ដោយសារជិតដល់ពេលបោះឆ្នោតរដ្ឋសភាជាតិប្រហែលបានរួមចំណែកបង្កការធ្លាក់ចុះវិនិយោគនេះ ។ នៅត្រីមាសទី១ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ដោយ អ្នកវិនិយោគចិន បានឈានមុខគេក្នុងឧស្សាហកម្មនៅកម្ពុជា (តំលៃវិនិយោគ ២១,១លានដុល្លារ) និងបន្ទាប់មកគឺ កូរ៉េខាងត្បូង (១១,៥លានដុល្លារ) ។ ក្នុងអនុមតិគំរោងឧស្សាហកម្ម គំរោងកាត់ដេរមាន ៤២,៣លានដុល្លារ រឺថយចុះ ៣៩% ធៀបនឹង ត្រីមាសមុន ។ វិនិយោគខាងសេវាកម្ម បានផ្តោតសំខាន់លើគំរោងទូរគមនាគមន៏ (២៤%នៃវិនិយោគខាងសេវាកម្មសរុប) ការសាងសង់កន្លែងលំហែកំសាន្ត និងផ្សារទំនើបធំៗ ។ គំរោងដែលបានស្នើឡើងក្នុងវិស័យទាំងបីនេះ នឹងប្រើពលករសរុប ៣១.៩៧១នាក់ ប្រសិនបើអនុវត្តបានពេញលេញទាំងអស់ ។

តំលៃអនុមតិគំរោងសាងសង់នៅភ្នំពេញថយចុះ ២០% ធៀបនឹងត្រីមាសមុនមកត្រឹម ១៣៧,៣លានដុល្លារ ។ អនុមតិគំរោងសាងសង់ផ្ទះល្វែងធ្លាក់ចុះ ៩,៤% មកត្រឹម ៥២,២លានដុល្លារ រីឯអនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ កើនឡើងមួយជាពីរ ដល់ ៤៤,២លានដុល្លារ ។ តំលៃសរុបនៃអនុមតិគំរោងសាងសង់នេះ គឺសំរាប់ ១៥០គំរោង ។ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧ អនុមតិគំរោងសាងសង់សរុបធ្លាក់ចុះ ១,៤% ក្នុងនេះ ខាងសំណង់ផ្ទះល្វែងធ្លាក់ចុះ ៤១% រីឯសំណង់ភូមិគ្រឹះ និងផ្ទះ កើនឡើងមួយជាបី ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ពាណិជ្ជកម្មកើនឡើងបន្តិច ធៀបនឹងត្រីមាសមុន ។ ឱនភាពពាណិជ្ជកម្មបានប្រសើរឡើង ដោយថយចុះពី ១៨៩,៣លានដុល្លារ មកត្រឹម ១៨០,៧លានដុល្លារ ។ ការនាំចេញរបស់កម្ពុជាដែលសឹងតែជាផលិតផលកាត់ដេរទាំងអស់ កើនឡើង ១,២% ដល់ ៨០៣,១លានដុល្លារ ។ ការនាំចេញខាងវិស័យឧស្សាហកម្ម កើនឡើង ៦,៤% ដល់ ៧៧៣,៤លានដុល្លារ រីឯការនាំចេញខាងវិស័យកសិកម្មថយចុះដែលក្នុងនេះការនាំចេញកៅស៊ូថយចុះ ៥២% មកត្រឹម ៧,០លានដុល្លារ ហើយការនាំចេញត្រីថយចុះ ២២% មកត្រឹម ០,៧លានដុល្លារ ។

ធៀបនឹងត្រីមាសមុន ការនាំចូលរបស់កម្ពុជានៅថេរត្រឹម ៩៨៣,៨លានដុល្លារ ។ ក្នុងនោះ តំលៃនាំចូលប្រេងកាតកើនឡើងបន្តិច ដល់ ៦០,០លានដុល្លារ រីឯការនាំចូលយានយន្ត និងគ្រឿងបន្លាស់កើន ៣២% ដល់ ១០២,៥លានដុល្លារ ។ ការនាំចូលសំភារៈសំនង់មានតំលៃ ៣៩,៧លានដុល្លារ រឺកើន ២២% ធៀបនឹងត្រីមាសមុន។ ការនាំចូលដែក កើន ៦៩% ដល់ ១៥,៨លានដុល្លារ រីឯការនាំចូលស៊ីម៉ង់ត៍ថយចុះ ៤,៥% មកត្រឹម ១១,៦លានដុល្លារ ។ ការនាំចូលក្រណាត់នៅថេរដដែល គឺ ១,៨លានដុល្លារ រីឯការនាំចូលសំលៀកបំពាក់ប្រើហើយថយចុះ ១៤% មកត្រឹម ១២,៩លានដុល្លារ ។ ការនាំចូលស្ករសកើនឡើង ២៣% ដល់ ២,៤លានដុល្លារ ហើយការនាំចូលស្រាបៀរកើន ៨,៦% ដល់ ៥,២លានដុល្លារ ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ភ្ញៀវមកដល់កម្ពុជាកើនឡើង ៦,០% ធៀបនឹងត្រីមាសមុន ដល់ ៦៤៤.២០៥នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាសកើន ៩,០% ដល់ ៤០២.០២៣នាក់ ក្នុងនេះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទទួលបាន ៤១% ។ ភ្ញៀវមកដល់តាមផ្លូវទឹកកើនយ៉ាងខ្លាំងបាន ៩២% ធៀបនឹងត្រីមាសមុន ដល់ ២៧.២៣២នាក់ ដែលបង្ហាញពីការពេញនិយមនៃដំណើរតាមផ្លូវទឹក ។ ភ្ញៀវមកដល់តាមផ្លូវគោក ថយចុះបន្តិចអស់ ៤,៥% មកត្រឹម ២១៤.៩៥០នាក់ ។ ភ្ញៀវមកសំរាកលំហែកើន ២១% ដល់ ៥៨០.១៦៩នាក់ រីឯភ្ញៀវមកធ្វើជំនួញថយចុះ ១១% មកត្រឹម ៣៧,៤៤៤នាក់ ។ ភ្ញៀវមកដល់ខេត្តសៀមរាបមាន ៥៥% នៃចំនួនភ្ញៀវសរុបមកកម្ពុជា រឺកើន ១២% ធៀបនឹងត្រីមាសមុន ។ កូរ៉េខាងត្បូងជាប្រទេសនាំមុខគេខាងភ្ញៀវធ្វើដំណើរមកកម្ពុជា (៩៧.៥៣៦នាក់) ហើយបន្ទាប់មក គឺ ជប៉ុន (៥៤.១៤៩នាក់) និង វៀតណាម (៥៣.៣៨៦នាក់) ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០០៨ រដ្ឋាភិបាលមានអតិរេកថវិកាចំនួន ១៣៥,០ពាន់លានរៀល ។ ចំនូលកើនឡើង ៤៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧ ដល់ ១១៩៤,១ពាន់លានរៀល ។ ចំនូលពន្ធកើន ៤០% ដល់ ៩៧៨,០ពាន់លានរៀល ក្នុងនេះ ចំនូលពន្ធក្នុងស្រុកមាន ៧១៩,៩ពាន់លានរៀល (រឺកើន ៤៨%) ហើយចំនូលពន្ធលើពាណិជ្ជកម្មអន្តរជាតិមាន ២៥៨,១ពាន់លានរៀល (រឺកើន ២២%) ។ ចំនូលមិនមែនពន្ធកើនឡើងច្រើនគួរសមបាន ៦៩% ដល់ ២១១,៤ពាន់លានរៀល ។ ចំនូលបានពីទ្រព្យសម្បត្តិ (ដូចជា ការជួលដីរដ្ឋ និងសហគ្រាសរដ្ឋ) ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៩០% មកត្រឹម ២,៩ពាន់លានរៀល ។ ចំនូលបានពីការលក់ទំនិញ និង សេវា (ដូចជា ការផ្តល់អាជ្ញាប័ណ្ណទីផ្សារនិងមិនមែនទីផ្សារ កំរៃរដ្ឋបាល កំរៃឈ្នួល និងពន្ធព្រលានយន្តហោះ) កើនឡើង ៣៤% ដល់ ១១៨,៩ពាន់លានរៀល ។ ចំនូលមូលធនដែលជាប្រភពចំនូលគ្មានស្ថិរភាព បានកើនពីចំនូល 0 នៅត្រីមាសទី១ ឆ្នាំ២០០៧ ដល់ ៤,៨ពាន់លានរៀល នៅត្រីមាសទី១ ឆ្នាំ២០០៨ ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ចំនាយរបស់រដ្ឋាភិបាលកើនដល់ ១០៥៩,១ពាន់លានរៀល រឺកើន ១៥% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៧ ។ ចំនាយចរន្តដែលជាធម្មតាមានចំនួនច្រើនជាងគេបំផុត នៅថ្ងៃបិទបញ្ជីគណនី (ចុងត្រីមាសទី៤) កើន ១៦% ដល់ ៦៤៨,១ពាន់លានរៀល ។ ចំនាយលើប្រាក់បៀវត្សរ៍កើន ២៦% ដល់ ២៥០,៧ពាន់លានរៀល និង ចំនាយមិនមែនប្រាក់បៀវត្សរ៍កើន ៥៦% ដល់ ២៦២,៨ពាន់លានរៀលដែលក្នុងនេះ ចំនាយលើការទិញ សំភារៈការិយាល័យ និងសំភារៈផ្គត់ផ្គង់ផ្សេងៗទៀត កើន ៩៣% ដល់ ៦៤,៥ពាន់លានរៀល ហើយ ចំនាយលើជំនួយសង្គមកិច្ច និងឧបត្ថម្ភធន កើន ៦៨% ដល់ ១០៤,៣ពាន់លានរៀល ។ ចំនាយមូលធន មាន ៤១១,០ពាន់លានរៀល រឺកើន ១២% ធៀបនឹង ត្រីមាសដូចគ្នាឆ្នាំមុន ។ ក្នុងចំនាយមូលធនសរុប មាន ៧៦% ដោះស្រាយដោយប្រភពទុនខាងក្រៅ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## អតិផរណា និង អត្រាប្តូរប្រាក់បរទេស

នៅខែមករា ២០០៨ ថ្លៃទំនិញប្រើប្រាស់កើនឡើងយ៉ាងខ្លាំង ។ ការឡើងថ្លៃទំនិញអន្តរជាតិ បានប៉ះពាល់យ៉ាងខ្លាំងដល់កម្ពុជាដែលជាប្រទេសពឹងផ្អែកខ្លាំងលើការនាំចូល ។ នៅខែមករា ២០០៨ ថ្លៃទំនិញជារួម កើន ១៨,៧% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ធៀបនឹងអត្រាឡើងថ្លៃ ១៦,៣% សំរាប់ខែធ្នូ ២០០៧ ។ ថ្លៃម្ហូបអាហារ និង ភេសជ្ជៈគ្មានជាតិស្រា កើន ២៤,២%។ ថ្លៃដឹកជញ្ជូនកើន ១០,២% ថ្លៃអប់រំកើន ៩,២% រីឯថ្លៃទូរគមនាគមន៍ធ្លាក់ចុះ ១២,៩% ។ ទន្ទឹមគ្នានេះ ថ្លៃសំលៀកបំពាក់ និងស្បែកជើង កើន ៨,៣%។ បំរែបំរួលថ្លៃទំនិញ និងសេវា រងឥទ្ធិពលយ៉ាងខ្លាំងពីថ្លៃប្រេងកាតក្នុងពិភពលោក ។ នៅត្រីមាសទី១ ឆ្នាំ២០០៨ សាំងលក់ថ្លៃជាមធ្យម ៤៥៨០រៀល/លីត្រ កើន ៤,៨% ធៀបនឹងត្រីមាសមុន ហើយម៉ាស៊ូតលក់ថ្លៃ ៣៩៨២ រៀល/លីត្រ កើន ៨,២% ។

ទល់នឹងដុល្លារUS ប្រាក់រៀលឡើងថ្លៃ ០,៩% ធៀបនឹងត្រីមាសមុន ដោយប្តូរបាន ៣៩៩៥រៀល/ដុល្លារUS។ ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម តំលៃប្រាក់រៀលនៅថេរ ដោយប្តូរបាន ១២៩,១រៀល/បាត និង ២៥,២រៀល/១០០ដុង។

## ការវិវត្តរូបិយវត្ថុ

នៅចុងខែមីនា ២០០៨ រូបិយវត្ថុទូទៅ (M2) រួមមាន ប្រាក់រៀលចរាចរ និងផ្ញើទុកក្នុងប្រព័ន្ធធនាគារ កើន ៥៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧ ដល់ ១២.០៤៧,២ពាន់លានរៀល។ ទន្ទឹមគ្នានេះ ប្រាក់រៀលចរាចរ កើន ៣៤% ដល់ ២៣២៤,០ពាន់លានរៀល ប្រាក់បញ្ញើជារៀលកើន ២៣% ដល់ ១៩១,០ពាន់លានរៀល ហើយប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៦១% ដល់ ៩៥៣២,៣ពាន់លានរៀល ។

កំនើនជាបន្តបន្ទាប់នៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធ បានបង្កើនបរិមាណសរុបនៃរូបិយវត្ថុទូទៅ (M2) ។ នៅខែមីនា ទ្រព្យសកម្មក្នុងស្រុកសុទ្ធក្នុងវិស័យធនាគារមានចំនួន ១១៣៦,៤ពាន់លានរៀល ដោយបានជាចំបងមកពីឥណទានក្នុងស្រុក ដែលកើនយ៉ាងខ្លាំងបាន ៩៥% ដល់ ៥៦៤៦,៩ពាន់លានរៀល ។ បំនុលផ្សេងទៀតក៏កើន ៤៣% ដល់ ៤៥១៣,៦ពាន់លានរៀលដែរ ។ ធាតុផ្សំនៃឥណទានក្នុងស្រុកដែលជាឥណទានរបស់រដ្ឋាភិបាល នៅថេរត្រឹម ២៩៦,៦ពាន់លានរៀល រីឯប្រាក់បញ្ញើរបស់រដ្ឋាភិបាលកើន ៨៣% ដល់ ២៦៩៧,០ពាន់លានរៀល ។ ឥណទានដល់វិស័យឯកជន កើន ៩៨% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៧ ដល់ ៨៤៣៩,០ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៣៥% ដល់ ១០៩១,៩ពាន់លានរៀល ។ ការប្រមូលសាច់ប្រាក់ដាក់បញ្ចូលវិញទៅក្នុងសកម្មភាពសេដ្ឋកិច្ចសហគ្រាសធុនតូចនិងមធ្យម បានជួយជំរុញកំនើន តាមរយៈការផ្តល់លទ្ធភាពប្រើប្រាស់កំលាំងពលកម្មបានកាន់តែច្រើនថែមទៀត ៕

*រៀបរៀងដោយ*
*ផាន់ ដាលីស និង ប៊ុន ដូរីណា*


## Cambodia Development Review—2008 Subscription Rates

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

❐ Thailand, Laos, Vietnam ❐ English edition ($25)* ❐ Khmer edition ($15)*
❐ Asia and Europe ❐ English edition ($30)* ❐ Khmer edition ($20)*
❐ Americas and Africa ❐ English edition ($35)* ❐ Khmer edition ($25)*

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to: Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❐Mr ❐Ms ❐Dr ❐Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 40.3 | 3.7 | 12.3 | 26.8 | 498.0 | 0.0 | 154.6 | 19.1 | 2.1 | 12.0 | 102.4 | 52.3 |
| ឧស្សាហកម្ម | 67.7 | 137.2 | 187.9 | 914.6 | 365.3 | 171.7 | 76.6 | 142.7 | 51.2 | 187.2 | 328.0 | 52.9 |
| *កាត់ដេរ* | *27.2* | *68.1* | *132.6* | *174.4* | *89.4* | *23.2* | *26.1* | *36.6* | *24.3* | *40.7* | *69.1* | *42.3* |
| សេវាកម្ម | 145.3 | 168.4 | 91.8 | 155.5 | 2939.1 | 94.5 | 740.7 | 335.7 | 138.0 | 957.7 | 311.1 | 148.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *47.1* | *124.1* | *55.9* | *102.6* | *345.0* | *3.5* | *315.3* | *140.3* | *55.0* | *653.8* | *199.2* | *93.7S* |
| សរុប | 253.3 | 309.3 | 292.0 | 1096.9 | 3802.4 | 266.2 | 971.9 | 497.5 | 191.3 | 1156.9 | 741.5 | 253.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | -88.6 | 265.1 | -48.8 | -61.6 | 504.7 | -35.9 | -65.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងឆ្នាំមុន | | | | | |
| សរុប | 13.1 | 22.1 | -5.6 | 275.6 | 246.6 | -34.1 | 715.4 | 118.9 | 91.8 | 334.6 | -23.7 | -49.1 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 23.4 | 20.0 | 30.3 | 45.5 | 33.1 | 7.6 | 9.7 | 14.4 | 22.8 | 21.7 | 20.2 | 44.2 |
| ផ្ទះល្វែង | 179.9 | 91.6 | 167.6 | 204.2 | 213.3 | 67.1 | 54.5 | 88.9 | 33.2 | 117.5 | 57.6 | 52.2 |
| ផ្សេងៗ | 16.6 | 87.3 | 65.6 | 109.1 | 76.8 | 20.8 | 13.9 | 35.9 | 88.8 | 40.6 | 94.3 | 40.9 |
| សរុប | 219.9 | 198.9 | 263.5 | 358.8 | 323.3 | 95.5 | 78.2 | 139.2 | 144.7 | 179.7 | 172.2 | 137.3 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | 16.1 | -18.1 | 78.0 | 3.9 | 24.2 | -4.2 | -20.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងឆ្នាំមុន | | | | | |
| សរុប | 12.0 | -9.5 | 32.5 | 36.2 | -9.9 | 24.8 | 8.9 | 106.5 | 76.0 | 88.2 | 120.2 | -1.4 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1453.2 | 1708.1 | 2108.1 | 2352.8 | 2799.9 | 807.5 | 736.7 | 707.8 | 705.0 | 890.8 | 793.4 | 803.1 |
| រួមមាន: សំលៀកបំពាក់ | 1355.8 | 1628.4 | 2027 | 2253.3 | 2698.9 | 782.0 | 716.0 | 677.5 | 688.2 | 846.1 | 727.1 | 773.4 |
| *- ទៅសហរដ្ឋអាមេរិក* | 943.4 | 1099.8 | 1270.9 | 1546.1 | 1847.1 | 522.8 | 483.2 | 499.1 | 451.2 | - | - | - |
| *- ទៅសហគមន៍អឺរ៉ុប* | 356.3 | 414.7 | 590.8 | 503.1 | 601.0 | 188.1 | 160.1 | 106.3 | 163.1 | - | - | - |
| *- ប្រទេសផ្សេងទៀត* | 56.1 | 113.8 | 165.3 | 204.1 | 250.7 | 71.0 | 72.8 | 72.0 | 73.8 | - | - | - |
| កសិកម្ម | 97.3 | 79.7 | 81.2 | 99.5 | 101.1 | 25.5 | 20.7 | 30.3 | 16.8 | - | - | - |
| *- កៅស៊ូ* | 29.7 | 35.1 | 38.3 | 36.7 | 41.4 | 13.6 | 10.2 | 8.4 | 6.9 | 11.7 | 14.6 | 7.0 |
| *- ឈើ* | 16.0 | 10.2 | 11.1 | 10.3 | 8.6 | 2.5 | 1.7 | 2.1 | 2.0 | 0.0 | 0.0 | 0.0 |
| *- ត្រី* | 4.3 | 2.8 | 10.6 | 10.1 | 5.9 | 1.6 | 1.4 | 0.7 | 0.4 | 1.2 | 0.9 | 0.7 |
| *- ផ្សេងៗ* | 47.4 | 31.6 | 21.3 | 42.6 | 45.1 | 7.7 | 7.5 | 19.0 | 7.5 | - | - | - |
| ការនាំចូលសរុប | 1707.8 | 1824.9 | 2149.0 | 2513.0 | 3057.0 | 784.3 | 807.1 | 790.9 | 911.6 | 924.5 | 982.7 | 983.8 |
| រួមមាន: ផលិតផលប្រេងកាត | 157.5 | 191.6 | 187.0 | 184.8 | 238.5 | 62.4 | 58.7 | 66.5 | 68.5 | 71.0 | 58.9 | 60.0 |
| សាំង | 25.9 | 33.2 | 30.2 | 40.2 | 49.6 | 13.1 | 13.2 | 15.7 | 20.2 | - | - | - |
| ម៉ាស៊ូត | 100.8 | 109.6 | 109.4 | 93.1 | 122.0 | 30.1 | 27.2 | 31.9 | 36.6 | - | - | - |
| សំភារៈសំណង់ | 12.9 | 80.8 | 95.3 | 134.7 | 154.4 | 42.5 | 35.8 | 44.1 | 31.6 | 34.9 | 32.5 | 39.7 |
| ផ្សេងៗ | 1568.2 | 1601.3 | 1914.0 | 2245 | 2731.0 | 698.5 | 731.0 | 699.2 | 807.5 | 818.6 | 891.3 | 884.1 |
| ជញ្ជីងពាណិជ្ជកម្ម | -254.6 | -116.8 | -40.9 | -160.1 | -257.1 | 23.2 | -70.4 | -83.1 | -208.1 | -30.7 | -189.3 | -180.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | -118.9 | -403.4 | 18.0 | 150.4 | -85.2 | -14.1 | 6.4 |
| ការនាំចេញសរុប | - | - | - | - | - | 23.7 | -8.8 | -3.9 | 0.4 | 26.4 | -10.9 | 1.2 |
| ការនាំចូលសរុប | - | - | - | - | - | 1.2 | 2.9 | -2.0 | 15.3 | 1.4 | 6.3 | 0.1 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 9.2 | -54.1 | -64.9 | 291.4 | 19.8 | -76.2 | 52.0 | -5.0 | 70.0 | -232.3 | 1.6 | 14.2 |
| ការនាំចេញសរុប | 14.6 | 17.5 | 23.4 | 11.6 | 19.0 | 10.6 | 14.3 | 17.3 | 8.0 | 10.3 | 7.7 | 13.5 |
| ការនាំចូលសរុប | 13.7 | 6.9 | 17.8 | 16.9 | 21.6 | 24.0 | 16.8 | 14.5 | 17.6 | 17.9 | 21.7 | 24.4 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by NBC*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 523.0 | 456.0 | 626.1 | 856.5 | 1029.0 | 224.2 | 325.0 | 373.6 | 275.6 | 278.5 | 368.8 | 402.0 |
| តាមផ្លូវគោក និងទឹក | 263.5 | 245.0 | 428.9 | 565.1 | 672.9 | 146.4 | 191.0 | 177.2 | 148.9 | 153.3 | 239.2 | 242.2 |
| សរុប | 786.5 | 701.1 | 1055.0 | 1421.6 | 1701.9 | 370.6 | 516.0 | 550.8 | 424.5 | 431.8 | 608.0 | 644.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | 4.1 | 39.2 | 6.7 | -22.9 | 1.7 | 40.8 | 6.0 |
| | | | | | | | បំរែបំរួលជាភាគរយធៀបទឹងឆ្នាំមុន | | | | | |
| សរុប | 30.0 | -10.9 | 50.5 | 34.7 | 19.7 | 14.7 | 24.1 | 20.4 | 19.2 | 16.5 | 17.8 | 17.0 |

*Source: Ministry of Tourism*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០២-០៨ (ពាន់លានរៀល)

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4* | Q1 |
| ចំណូលសរុប | 1744 | 1764 | 2126 | 2625 | 3259.2 | 732.2 | 1199.6 | 824.9 | 1016.8 | 1031.4 | 1146.1 | 1194.1 |
| ចំណូលចរន្ដ | 1728 | 1733 | 2107 | 2474 | 2881.8 | 716.8 | 844.9 | 824.9 | 1012.4 | 1031.4 | 1141.6 | 1189.4 |
| ចំណូលពន្ធ | 1227 | 1220 | 1577 | 1911 | 2270.9 | 565.8 | 661.8 | 699.9 | 887.7 | 844.6 | 965.2 | 978.0 |
| ពន្ធគយ | 424 | 395 | 513 | 573 | 644.4 | 157.2 | 200.0 | - | - | - | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | 487.9 | 642.1 | 584.8 | 661.8 | 719.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | 212.1 | 245.6 | 259.8 | 303.5 | 258.1 |
| ចំណូលមិនមែនពន្ធ | 501 | 513 | 530 | 563 | 610.9 | 151.0 | 183.1 | 125.0 | 124.7 | 186.9 | 176.4 | 211.4 |
| អាជីវកម្មព្រៃឈើ | 15 | 7 | 2 | 3 | 2 | 0.3 | 0.9 | - | - | - | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 123 | 120 | 94 | 123 | 83.1 | 11.7 | 30.0 | - | - | - | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 | 2.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | 88.8 | 93.0 | 100.1 | 124.3 | 118.9 |
| ចំណូលជាមូលធន | 16 | 31 | 19 | 152 | 377.4 | 15.4 | 354.7 | 0.0 | 4.5 | 0.0 | 4.5 | 4.8 |
| ចំណាយសរុប | 2948 | 2757 | 2932 | 3295 | 4174.7 | 1030.6 | 1191.9 | 923.9 | 1098.7 | 1126.1 | 1689.7 | 1059.1 |
| ចំណាយជាមូលធន | 1388 | 1171 | 1163 | 1328 | 1638.1 | 423.8 | 429.1 | 367.1 | 408.1 | 355.1 | 807.4 | 411.0 |
| ចំណាយចរន្ដ | 1560 | 1586 | 1769 | 1967 | 2536.8 | 606.9 | 762.8 | 556.8 | 681.6 | 771.0 | 882.3 | 648.1 |
| អប់រំ និងសុខាភិបាល | 454 | 473 | 518 | 351 | 714.0 | 150.1 | 281.3 | - | - | - | - | - |
| ការពារជាតិ និងសន្ដិសុខជាតិ | 438 | 411 | 423 | 451 | 520.2 | 155.3 | 170.1 | - | - | - | - | - |
| ក្រសួងផ្សេងៗទៀត | 668 | 702 | 828 | 1165 | 1302.5 | 301.5 | 311.4 | - | - | - | - | - |
| បៀវត្សរ៍ | 587 | 615 | 640 | 711 | 822.0 | 230.6 | 240.6 | 199.7 | 242.7 | 253.4 | 362.6 | 250.7 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | - | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 | 104.3 |
| សមតុល្យជាទូទៅ | -1204 | -993 | -806 | -706 | -915.6 | -298.5 | 7.7 | -99.0 | -81.9 | -78.7 | -543.6 | 135.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1249 | 886 | 864 | 1127 | 1360.7 | 335.2 | 376.2 | 344.0 | 313.9 | 290.3 | 741.5 | 299.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -45 | 106 | 148 | -396 | -445.1 | -36.7 | -383.9 | -245.0 | -213.0 | -148.0 | -185.8 | -294.1 |

*Provisional for 2007. Source: MEF web site. * revised data*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (October-December 2006:100) | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1* |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | - | - | - | - | - | - | 5.9 | 9.0 | 14.4 | 16.6 | 19.1 |
| ភ្នំពេញ | - | - | - | - | - | - | - | 4.7 | 5.8 | 7.7 | 12.4 | 16.8 |
| កម្ពុជា - ទំនិញគ្រប់ប្រភេទ | - | - | - | - | - | - | - | 5.7 | 8.5 | 11.9 | 15.9 | 18.7 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | - | - | - | 8.3 | 12.0 | 16.9 | 21.7 | 24.2 |
| - ដឹកជញ្ជូន | - | - | - | - | - | - | - | -3.4 | 1.1 | 2.0 | 5.3 | 10.2 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3912.1 | 3973.3 | 4016.3 | 4119.7 | 4119.0 | 4145.3 | 4129.4 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 |
| រៀលក្នុង ១ បាតថៃ | 91.1 | 95.8 | 99.9 | 102.6 | 108.7 | 110.3 | 113.0 | 113.7 | 118.0 | 130.0 | 129.3 | 129.1 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.6 | 25.5 | 25.8 | 25.1 | 24.9 | 25.0 | 24.6 | 24.7 | 25.3 | 25.2 | 25.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.8 | 41.4 | 46.3 | 54.0 | 70.6 | 73.0 | 72.8 | 77.7 | 79.8 | 80.8 | 94.4 | 111.6 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1521 | 1508 | 2088 | 2633 | 3140.0 | 3333 | 3250 | 3067 | 3100 | 3203 | 3679 | 3982 |
| ថ្លៃសាំង (រៀល/លីត្រ) | 2084 | 2150 | 2833 | 3442 | 4004.3 | 4200 | 4050 | 3750 | 3900 | 4002 | 4368 | 4580 |

*Sources: NIS, NBC & CDRI. *The data for consumer price index are available to January 2008.*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០២-០៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3737 | 4027 | 4797 | 5475 | 6682 | 6958 | 7224 | 8056 | 9048 | 9768 | 10735 | 10911 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -849 | -698 | -467 | -450 | -637 | -497 | -282 | -263 | -172 | 140 | 576 | 1136 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -119 | -128 | -209 | -421 | -831 | -892 | -953 | -1176 | -1403 | -1547 | -1816 | -2400 |
| ឥណទានដល់ផ្នែកឯកជន | 1059 | 1337 | 1817 | 2394 | 2997 | 3288 | 3628 | 4066 | 4537 | 5376 | 6386 | 8050 |
| រូបិយវត្ថុទូទៅ M2 | 2888 | 3329 | 4330 | 5025 | 6045 | 6461 | 6942 | 7793 | 8876 | 9908 | 11311 | 12047 |
| រូបិយវត្ថុ M1 | 813 | 937 | 1153 | 1323 | 1512 | 1563 | 1658 | 1794 | 1748 | 1750 | 2052 | 2389 |
| រូបិយវត្ថុផ្សេងៗ | 2075 | 2392 | 3177 | 3702 | 4533 | 4898 | 5285 | 5999 | 7128 | 8158 | 9259 | 9658 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 31.0 | 15.2 | 30.0 | 16.1 | 30.6 | 29.4 | 38.2 | 36.5 | 46.8 | 53.4 | 62.9 | 54.5 |
| រូបិយវត្ថុ M1 | 33.5 | 15.3 | 23.0 | 14.7 | 24.4 | 22.2 | 25.3 | 23.9 | 15.7 | 12.0 | 23.8 | 33.2 |
| រូបិយវត្ថុផ្សេងៗ | 30.0 | 15.2 | 32.8 | 16.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 | 66.5 | 75.2 | 61.0 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2007 | | |
| | វិច្ឆិកា | | | | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 6534 | 9245 | 7126 | 9393 | 8 | 18 | 27 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 6010 | 9798 | 7704 | 8852 | 33 | 47 | 26 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 6125 | 8951 | 9116 | 8303 | 38 | 75 | 36 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 4530 | 5533 | 6038 | 5560 | 23 | 42 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4078 | 5150 | 4193 | 4508 | 21 | -2 | 0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4126 | 4531 | 4561 | 4790 | 0 | 10 | 3 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 11146 | 8347 | 9033 | 8207 | 6 | -2 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 9144 | 12,886 | 8979 | 13,060 | 47 | 33 | 37 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5263 | 6075 | 5901 | 7550 | -5 | -2 | 43 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 10,215 | 11,892 | 11,723 | 10,956 | 21 | 24 | 7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

## តពីទំព័រ ៧ ការសិក្សាពីឌីណាមិក ...

### កំណត់សំគាល់

១. បន្ថែមពីលើការកសាងសមត្ថភាពក្នុងការវិភាគ និងប្រមូលទិន្នន័យបែបបរិមាណនិងគុណភាព ជំនួយហិរញ្ញវត្ថុដែលទទួលបានពីការិយាល័យខាងភាពក្រីក្រនៃធនាគារពិភពលោក ក៏សំរាប់ចំណាយលើសកម្មភាពស្រាវជ្រាវសំខាន់ៗ ដូចជា ការរចនារៀបចំវិធីសាស្ត្រស្រាវជ្រាវ ការប្រមូល/បញ្ចូល/សំអាតទិន្នន័យបែបបរិមាណនិងគុណភាព និង ការបង្កើតឯកសារគោលនយោបាយស្ដីពី ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារទៅលើសន្តិសុខស្បៀង ផលិតកម្មកសិកម្ម និង ការកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែ CDRI និង ធនាគារពិភពលោក ត្រូវស្វែងរកជំនួយបន្ថែមសំរាប់ការចាត់ចែង និងវិភាគទិន្នន័យឱ្យកាន់តែទូលំទូលាយដើម្បីកសាងឯកសារគោលនយោបាយ ៤ ទៀត, បង្កើតរបាយការណ៍ជាភាសាខ្មែរ និងអង់គ្លេស, ធ្វើការផ្សព្វផ្សាយគោលនយោបាយ ព្រមទាំងការសន្ទនា ដែលមានប្រយោជន៍ ចំពោះអ្នកបង្កើតគោលនយោបាយ ។

២. ការពិភាក្សាលំអិត អាចស្វែងរកបានក្នុងឯកសារបច្ចេកទេសរបស់ CDRI "តើបទពិសោធន៍អ្វីខ្លះដែលយើងទទួលបានពីការសិក្សាពី ការចាកផុតពីភាពក្រីក្រ (MOPS)?" ៕

### ឯកសារយោង


Ballard, B. (ed.) (2007), *'We are living with worry all the time': A participatory poverty assessment of the Tonle Sap* (Phnom Penh: CDRI)

CDRI (2007a), *Cambodia Land Titling Rural Baseline Survey Report* (Phnom Penh: CDRI)

CDRI (2007b), *Pro-Poor Tourism in the Greater Mekong Sub-Region* (Phnom Penh: CDRI)

FitzGerald, I. & So Sovannarith (2007), *Moving Out Of Poverty: Trends in Community Well-Being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI)

IRL (2007), *Perceptions of inequality in Cambodia: a survey* (Phnom Penh: Indochina Research Limited)

National Institute of Public Health, National Institute of Statistics & ORC Marcro (2006), *Cambodia Demographic and Health Survey 2005* (Calverton, MD: ORC Macro; Phnom Penh: National Institute of Statistics and Directorate General for Health)

National Institute of Statistics, Ministry of Planning, Ministry of Health & ORC Macro (2001), *Cambodia Demographic and Health Survey 2000* (Phnom Penh and Calerton, MD: NIS)

World Bank (2007), *Sharing Growth: Equity and Development in Cambodia: Equity and Development Report 2007* (Phnom Penh: World Bank)

World Bank (2006), *Cambodia: Halving Poverty by 2015?: Poverty Assessment 2006* (Phnom Penh: World Bank)


---

## តពីទំព័រ ១១ កម្មវិធីអត្តសញ្ញាណកម្ម ...

លើតំបន់ដែលមូលនិធិសមធម៌សុខភាព កំពុងដំណើរ ។ ក្រសួងផែនការ ផ្ដល់ការបណ្ដុះបណ្ដាល និងការណែនាំដល់អង្គការទាំងនោះ ។

ក្រសួងផែនការមានទិសដៅអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងតំបន់ជនបទទូទាំងប្រទេសកម្ពុជានៅប៉ុន្មានឆ្នាំខាងមុខ និងធ្វើបច្ចុប្បន្នភាពបញ្ជីគ្រួសារក្រីក្រជាប្រចាំ ហើយដើម្បីសម្រេចឱ្យបាននៅទិសដៅនេះ ក្រសួងផែនការត្រូវការនូវធនធានបន្ថែមទៀត ។ ក្នុងឆ្នាំ២០០៩ ក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍របស់ខ្លួននឹងបង្កើតកញ្ចប់ថវិកាជំនួយរួម (Multi-Donor Trust Fund) ដែលក្នុងក្របខ័ណ្ឌកញ្ចប់ជំនួយនេះ រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា នឹងមានលទ្ធភាពរួមចំណែកក្នុង ការផ្ដល់ថវិកាសំរាប់គាំទ្រកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ កញ្ចប់ថវិកានេះ នឹងធានាចីរភាពនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការចែករំលែកទិន្នន័យជាមួយអ្នកផ្ដល់សេវា ទាំងស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្ដល់នូវផលប្រយោជន៍ ដ៏ទូលំទូលាយដល់គ្រួសារក្រីក្រ ។

គោលបំណងសំខាន់មួយទៀតរបស់ក្រសួងផែនការ គឺសហការឱ្យបានជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ដើម្បីសម្រេចឱ្យបាននូវការធ្វើសមាហរណកម្មអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទៅក្នុងក្របខ័ណ្ឌការងារក្រុមប្រឹក្សាឃុំ និងរចនាសម្ព័ន្ធគាំទ្រក្រុមប្រឹក្សាឃុំ (អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត និងក្រុមសម្របសម្រួលថ្នាក់ខេត្តនិងស្រុក) ។ ការធ្វើសមាហរណកម្មនេះ នឹងជួយជំរុញចីរភាពរយៈពេលវែងនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រទូលំទូលាយដោយក្រុមប្រឹក្សាឃុំ ជាឧបករណ៍សំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ ។ ក្រសួងផែនការ នឹងស្វែងរកធនធានសម្រាប់គាំទ្រសកម្មភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅថ្នាក់ឃុំនិងភូមិ ។ ធនធានទាំងនេះគួរតែផ្ដល់តាមរយៈមូលនិធិឃុំជាការប្រសើរ ។

កិច្ចការសំខាន់មួយទៀត គឺជំរុញការប្រើប្រាស់ទូលំទូលាយនូវទិន្នន័យដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល កម្មវិធីនិងគម្រោងតាមវិស័យក៏ដូចជាក្រុមប្រឹក្សាឃុំ ជាឧបករណ៍សម្រាប់ផ្ដល់សេវានិងជំនួយដល់គ្រួសារក្រីក្រ ។ ក្រៅពីការរៀបចំសិក្ខាសាលាផ្សព្វផ្សាយទិន្នន័យគ្រួសារក្រីក្រនៅថ្នាក់ខេត្តនិងស្រុក កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការនឹងធ្វើការផ្សព្វផ្សាយនៅថ្នាក់ជាតិ ដើម្បីលើកកំពស់ការយល់ដឹងអំពីកម្មវិធីនិងដើម្បីផ្សព្វផ្សាយទិន្នន័យ ។ ក្រៅពីបទបង្ហាញដល់ក្រុមការងារបច្ចេកទេស និងវេទិកាផ្សេងទៀត សិក្ខាសាលាថ្នាក់ជាតិមួយដើម្បីចាប់ផ្ដើមប្រើប្រាស់នីតិវិធីថ្នាក់ជាតិជាផ្លូវការ គ្រោងធ្វើនៅត្រីមាសទី ៤ ឆ្នាំ២០០៨ ៕

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ ...**

ពលកម្មនៅ GMS និង ពាណិជ្ជកម្មកសិកម្មនៅ GMS ។ កញ្ញា អ៊ូច ច័ន្ទតារានី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតខាងគោលនយោបាយសាធារណៈ នៅសាលាគោលនយោបាយសាធារណៈ Lee Kuan Yew នៃសាកលវិទ្យាល័យជាតិនៃសិង្ហបុរី ។

**ផ្នែកសន្តិសុខមនុស្ស កសាងសន្តិភាព និងបំបែ្លងទំនាស់** បានបញ្ចប់រួចរាល់ការចុះស្រាវជ្រាវដល់កន្លែងនៅតាមខេត្តចំនួន ៦ ដើម្បីវិភាគពីស្ថានភាពយុវជន។ ផ្នែកនេះបានចាប់ផ្តើមធ្វើវិភាគ និងសរសេររបាយការណ៍ ហើយគ្រោងយកជំពូកមួយនៃរបាយការណ៍នេះ ទៅចុះនៅក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ។ ក្រុមស្រាវជ្រាវនៃ ការសិក្សាពីភាពក្រីក្រ របស់កុមារនិងវិសមភាព បានជឿនលឿនទៅមុខក្នុងការធ្វើវិភាគ ហើយសង្ឃឹមថា នឹងបញ្ចប់របាយការណ៍នៅចុងខែកញ្ញា ។ អ្នកស្រាវជ្រាវពីរនាក់ បានទទួលការឧបត្ថម្ភពី UNICEF អោយទៅចូលរួម ការសិក្សាសកលពីភាពក្រីក្ររបស់កុមារនៅឯប្រទេសអង់គ្លេស ចាប់ពីថ្ងៃទី១៦ ដល់ ២៨ ខែកញ្ញា ។ ផ្នែកនេះកំពុងកែប្រែខ្លួនជាបណ្តើរៗដើម្បីក្លាយជាផ្នែកអភិវឌ្ឍន៍សង្គមវិញ ដែលមានការងារគ្របដណ្តប់លើវិស័យមួយចំនួន ដូចជា សុខភាព ការអប់រំ និងសន្តិសុខមនុស្ស ។ ផ្នែកនេះកំពុងស្វែងរកមូលនិធិបន្ថែមទៀតពីប្រភពផ្សេងៗ និងកំពុងពិនិត្យឡើងវិញនូវសំណើគំរោងមួយខាងការថែទាំសុខភាព ដោយបានពិភាក្សាជាមួយនាយកដ្ឋានផែនការសុខាភិបាល អង្គការសុខភាពពិភពលោក (WHO) និង វិទ្យាស្ថានគោលនយោបាយសុខាភិបាល Oxford ។

**ផ្នែកធនធានធម្មជាតិ និងបរិស្ថាន** បានរៀបចំរបាយការណ៍ជឿនលឿនការងារប្រចាំឆ្នាំលើកទី២ និង ផែនការការងារ សំរាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវពីការគ្រប់គ្រងធនធានទឹក ។ របាយការណ៍ និងផែនការការងារ បានបញ្ជូនទៅទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) ដើម្បីសួរយោបល់ ហើយពេលនេះ របាយការណ៍បានចប់រួចរាល់សំរាប់ដាក់ជូន AusAID ជាសំរេច។ ឯកសារគោលគំនិតស្តីពីប្រធានបទសេដ្ឋកិច្ចនិងរូបវិន្ត ក្នុងចំនោមប្រធានបទទាំង៣ (សេដ្ឋកិច្ច, រូបវិន្ត និង អភិបាលកិច្ច) កំពុងតែបង្កើយអោយរួចរាល់ ។ ផ្នែកនេះ ក៏កំពុងបញ្ចប់ការវាយតំលៃសង្គមមួយស្តីពីការគ្រប់គ្រងធនធានទឹកនៅកម្ពុជា ។ ផ្នែកនេះថែមទាំងបានបង្កើយការចុះអង្កេតដល់កន្លែងលើកទី៣ សំរាប់គំរោងរួមគ្នាមួយស្តីពី ព្រៃត្រូពិកសំរាប់ការកាត់បន្ថយភាពក្រីក្រ ក្នុងប្រទេសចំនួន ៥ ដោយធ្វើវិភាគតាំងពីទិន្នន័យគ្រួសារ រហូតដល់កំរិតសកល ។ ចាប់តាំងពីខែកក្កដា គំរោងមួយស្តីពីការកសាងសមត្ថភាពសហគមន៍សំរាប់ការផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប ដែលទទួលថវិកាពី មូលនិធិជប៉ុនសំរាប់កាត់បន្ថយភាពក្រីក្រ ត្រូវបានផ្ទេរមកឱ្យផ្នែកនេះ ។ ដំណាក់កាលបំផុសគំនិតកសាងគំរោង នឹងបន្តរហូតដល់ខែកញ្ញា ហើយនេះជាគំរោងរួមគ្នាមួយរវាង CDRI, វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM-LI) និងក្រុមប្រឹក្សាសំរាប់កសិកម្មនិងអភិវឌ្ឍន៍ជនបទ (CARD) ។ ផែនការការងារបំផុសគំនិតមួយ ត្រូវបានយកមកពិនិត្យឡើងវិញ ។ អ្នកស្រាវជ្រាវនៃផ្នែកនេះ បានចូលរួមក្នុង វគ្គបណ្តុះបណ្តាលមូលដ្ឋាន រៀបចំឡើងដោយ CBNRM-LI ។ សព្វថ្ងៃ ផ្នែកនេះកំពុងធ្វើការលើ ឯកសារគោលគំនិតស្តីពីអង្កេតមូលដ្ឋាន ដោយរំពឹងថានឹងអាចបញ្ចប់នៅចុងខែសីហា ហើយការចុះអង្កេតមួយគ្រោងធ្វើឡើងនៅខែកញ្ញា ។

**ផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ** បានបំពេញសកម្មភាពមួយចំនួនក្នុងគំរោង ការសិក្សាពីឌីណាមិកនៃភាពក្រីក្រឆ្នាំ២០០៨-០៩ ដែលកំពុងដំណើរការ ។ មានបុគ្គលិក ២នាក់ បានទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលកំរិតខ្ពស់ របស់ធនាគារពិភពលោកស្តីពី ការវិភាគភាពក្រីក្របែបបរិមាណ ។ ផ្នែកនេះបានដំណើរការវគ្គបំប៉នអំពីវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព សំរាប់អ្នកស្រាវជ្រាវ និងជំនួយការស្រាវជ្រាវ ១២នាក់ មកពីផ្នែកស្រាវជ្រាវនានានៃ CDRI ។ ការងាររចនា និងត្រៀមរៀបចំសំរាប់ជុំទី២នៃអង្កេតគ្រួសារ និងការប្រមូលទិន្នន័យនៅខែកញ្ញា-តុលា ដំណើរការបានទាន់ពេលល្អ ។ ផ្នែកនេះ ក៏បានដាក់សំណើមួយទៅ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្រាវជ្រាវអន្តរជាតិ (IDRC) ដើម្បីស្វែងរក មូលនិធិបន្ថែមសំរាប់សកម្មភាពដែលនៅសេសសល់ក្នុងការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ។ ក្នុងកិច្ចសហការជាមួយ ផ្នែកសន្តិសុខមនុស្ស កសាងសន្តិភាព និងបំបែ្លងទំនាស់ ដើម្បីអនុវត្តគំរោងវិភាគស្ថានភាពយុវជន ផ្នែកនេះបាន ធ្វើការចុះអង្កេតដល់កន្លែងរួចស្រេចបាច់ ហើយការងារវិភាគទិន្នន័យនិងសរសេររបាយការណ៍លូតលាស់ទៅមុខទាន់ពេលល្អ ។ ផ្នែកនេះបានទទួលអ្នកហាត់ការមួយនាក់ ជានិស្សិតមកពីសកលវិទ្យាល័យក្រុងតូក្យូ ដែលធ្វើការសិក្សាពី តួនាទីមូលធនសង្គមក្នុងការអភិវឌ្ឍន៍សហគមន៍ ។

តាំងពីឆ្នាំ២០០៧ មក CDRI បានធ្វើសិក្ខាសាលាស្រាវជ្រាវ ២ដងក្នុងមួយខែ ស្តីពីបញ្ហាអភិវឌ្ឍន៍ផ្សេងៗ ។ សិក្ខាសាលា មានគោលដៅចែករំលែកលទ្ធផលស្រាវជ្រាវ និងពង្រឹងគុណភាពស្រាវជ្រាវតាមរយៈការពិភាក្សាលើរបកគំហើញផ្សេងៗ ការកែលំអវិធីសាស្ត្រ ការកំនត់គោលគំនិត/ការវិភាគពីប្រធានបទស្រាវជ្រាវ ។ វាគ្មិនក្នុងសិក្ខាសាលានេះ មានមកពី CDRI និងស្ថាប័ននានានៅក្រុងភ្នំពេញ។ ចាប់តាំងពីខែមិថុនា វាគ្មិនមកពីក្រៅមានជាអាទិ៍ លោក Steve Gniel និស្សិតថ្នាក់អនុបណ្ឌិតមកពីសកលវិទ្យាល័យជាតិអូស្ត្រាលី និងលោកស្រី Ogasawara Rie និស្សិតថ្នាក់បណ្ឌិតមកពីសកលវិទ្យាល័យគីយ៉ូតូ ប្រទេសជប៉ុន ។ វាគ្មិនមកពី CDRI មានជាអាទិ៍ លោក នូ កែវសុទ្ធា, ប៉ក់ គឹមជឿន, ច័ន្ទ សុផល, និង ភឹម រុនស៊ីណារិទ្ធិ ។ ប្រធានបទលើកមកបកស្រាយជាប់ទាក់ទងនឹងការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្មនិងធនធានធម្មជាតិ និង កសិកម្ម ៕

**ឯកសារចេញផ្សាយថ្មីរបស់វិទ្យាស្ថាន CDRI**


សង្ខេបសំរាប់ **គោលនយោបាយ**

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ 2008 លេខ 01

**បដិជុល្លារូបនីយកម្ម នៅប្រទេសកម្ពុជា: ១០ឆ្នាំកន្លងទៅ**

ដោយលោក ចាយ៉ាន់ មេណន់ *

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

របាយការណ៍ប្រចាំឆ្នាំ២០០៧-២០០៨ របស់វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានបោះពុម្ពផ្សាយ និងចុះក្នុងវេបសាយរួចរាល់ហើយ ។ ស្របតាមស្មារតីការប្រជុំបូកសរុបលទ្ធផលពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រ CDRI ឆ្នាំ២០០៦-២០១០ ហើយដើម្បីឆ្លើយតបនឹងតំរូវការក្នុងស្រុកយ៉ាងខ្លាំងនូវលទ្ធផលស្រាវជ្រាវ វិទ្យាស្ថាន CDRI ពេលនេះបានផ្ដល់ដោយឥតគិតថ្លៃរាល់របាយការណ៍ស្រាវជ្រាវ និងរបកគំហើញសំខាន់ៗរបស់ខ្លួនទាំងជាភាសាខ្មែរ និងអង់គ្លេស តាមរយៈការចុះក្នុងវេបសាយ ។ វិទ្យាស្ថាន ក៏បន្តចេញផ្សាយនូវឯកសារបោះពុម្ពមានគុណភាពល្អ ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវសំខាន់ៗ ដូចជា *របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ* និង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជាប្រចាំត្រីមាស* ។ បច្ចុប្បន្ន លទ្ធផលនៃសន្និសីទចក្ខុវិស័យឆ្នាំ២០០៨ ទាំងជាភាសាខ្មែរ និងអង់គ្លេស ក៏បានចុះរួចហើយដែរក្នុងវេបសាយរបស់ CDRI ។

នៅថ្ងៃទី១៥ សីហា ២០០៨ វិទ្យាស្ថាន CDRI បានធ្វើការប្រជុំពាក់កណ្ដាលឆ្នាំនៃក្រុមប្រឹក្សាភិបាល ដែលចូលរួមដោយសមាជិកក្នុងស្រុកទាំងអស់ ។ ក្រុមប្រឹក្សាភិបាលបានពិនិត្យលើរបាយការណ៍បណ្ដោះអាសន្នស្ដីពីទិសដៅនានា ដែលបានមកពីការប្រជុំបូកសរុបលទ្ធផលពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ដូចជា លទ្ធផលនៃការពិនិត្យបូកសរុបផ្ទៃក្នុងនៃដំណើរការធៀបនឹងទិសដៅផែនការ ការធ្វើអង្កេតពីការពេញចិត្តរបស់បុគ្គលិកដែលធ្វើឡើងដោយសហគ្រាសខាងក្រៅ ការពិនិត្យឡើងវិញពីតួនាទីនិងតំរូវការអភិវឌ្ឍន៍នៃអ្នកគ្រប់គ្រងថ្នាក់កណ្ដាល និងប្រាក់បៀវត្សរ៍ ហើយនិងបញ្ហាជាប់ពាក់ព័ន្ធខាងការគ្រប់គ្រងធនធានមនុស្ស ។ ក្រុមប្រឹក្សាភិបាលបានគាំទ្រ CDRI ចំពោះទិសដៅផ្ដោតការយកចិត្តទុកដាក់លើកំណែលំអគុណភាពស្រាវជ្រាវនិងការគ្រប់គ្រង សំរាប់រយៈពេលនៅសល់នៃផែនការ ដូចជា សំណើកែសំរួលរចនាសម្ព័ន្ធខ្លះនៃផ្នែកស្រាវជ្រាវ ការកសាងយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជា ឆ្នាំ២០២០ របស់ CDRI ការផលិតនិងចែកចាយផលិតផលស្រាវជ្រាវជាភាសាខ្មែរនិងអង់គ្លេសកាន់តែមានប្រសិទ្ធភាព ការកែសំរួលគោលនយោបាយនិងនីតិវិធីផ្ទៃក្នុង ការកែលំអគោលនយោបាយខាងបៀវត្សរ៍និងរក្សាទុកបុគ្គលិក នឹងវិធីសាស្ត្រធ្វើការអភិវឌ្ឍន៍ជាប្រព័ន្ធនូវសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក ។

## ផ្នែកស្រាវជ្រាវ

ពីខែមិថុនា ដល់ សីហា ២០០៨ វិទ្យាស្ថាន CDRI បានធ្វើសកម្មភាពស្រាវជ្រាវ និងសកម្មភាពទាក់ទងនឹងការស្រាវជ្រាវ តាមផ្នែកជំនាញដូចតទៅ:

**ផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់សាធារណៈ** បានទទួលការអញ្ជើញឱ្យចូលរួមក្នុងក្រុមប្រឹក្សារៀបចំ សំរាប់ជួយដល់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការតាក់តែង កម្មវិធីជាតិសំរាប់វិមជ្ឈការនិងវិសហមជ្ឈការ បន្ទាប់ពីការអនុម័តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ការសិក្សាស្ដីពីការដឹកនាំក្នុងនយោបាយនៅតាមមូលដ្ឋាន កំពុងតែធ្វើវិភាគ និងសរសេរឯកសារទី១ ក្នុងចំណោមឯកសារពិភាក្សាទាំង ៣ ដែលគ្រោងផ្សព្វផ្សាយ ។ ការសិក្សាពីអភិបាលកិច្ចខាងធនធាន មានដំណើរការយ៉ាងល្អ ដោយកំពុងសរសេររបាយការណ៍ និង ធ្វើការចុះស្រាវជ្រាវដល់កន្លែងមួយចំនួនថែមទៀត ។

**ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រត្តិការក្នុងតំបន់** បានធ្វើអង្កេតគ្រួសារថ្នាក់ជាតិមួយដើម្បីវាយតំលៃពី ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ និងបានបញ្ចប់អង្កេតនេះដោយជោគជ័យថ្វីបើមានពេលវេលាខ្លីក្ដីហើយ សិក្ខាសាលាថ្នាក់ជាតិមួយដើម្បីផ្សព្វផ្សាយរបកគំហើញផ្សេងៗ គ្រោងធ្វើឡើងនៅខែកញ្ញា ។ ការងារកំពុងដំណើរការ មានជាអាទិ ការសិក្សាពីសេវាកម្មនិងកំនើន, ភាពប្រកួតប្រជែង, សេដ្ឋកិច្ចនយោបាយនៃសមាហរណកម្មមហាអនុតំបន់មេគង្គ GMS, ការនាំចេញសេវាកម្ម, ចំណាកស្រុកកំលាំង

(តទៅទំព័រ ១៩)

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១២ លេខ៣ ខែកក្កដា_កញ្ញា ឆ្នាំ២០០៨

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង គឹម ចិត្រា
ជំនួយការកែសំរួល: ទូច ដារិទ្ធរង្សី
រោងពុម្ពព្រីនម៉ាស្ទ័រ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។